# ជំពូក ៨

# សម័យអង្គរ

## ក. គ្រាដំបូងនៃសម័យអង្គរ

### ១. ជ័យវរ្ម័នទី ២និងលទ្ធិទេវរាជ

សម័យអង្គរដែលអ្នកប្រវត្តិសាស្រ្តបានមូលមតិគ្នាចាត់ទុកថាជាសម័យមួយដ៏រុងរឿងបំផុតនៃសាវតារខ្មែរបានផ្ដើមឡើងជាមួយរជ្ជកាលរបស់ព្រះបាទ **ជ័យវរ្ម័ន**ទី២ ។ ក្នុងជំពូកមុនយើងបានឃើញថានៅចុងស.វ.ទី៨ប្រទេសខ្មែរត្រូវបែងចែកជាពីរគឺចេនឡាដីគោកនិងចេនឡាទឹកលិច ហើយចេនឡាទឹកលិចនេះទៀតសោតក៏ត្រូវបែងចែកជាក្សត្របុរីជាច្រើនវាតយកអំណាចតែរៀងៗខ្លួន ។ ឆ្លៀតយកឱកាសដែលខ្មែរកំពុងតែទន់ខ្សោយដោយបែកបាក់គ្នាយ៉ាងនេះជនជាតិជ្វាក្រោមការដឹកនាំរបស់រាជវង្សសៃលេន្ទ្របានលើកទ័ពមករាតត្បាតដុតបំផ្លាញក្រុងសម្ភុបុរ ចាប់បានព្រះរាជាខ្មែរហើយដាក់ប្រទេសខ្មែរជាចំណុះជ្វាថែមទៀត ។ គេមិនដឹងច្បាស់ថាក្សត្របុរីឯទៀតត្រូវទទួលវាសនាដូចសម្ភុបុរីដែលឬយ៉ាងណាទេ តែទោះជាក្សត្របុរីឯទៀតអាចគេចផុតពីចំណុះជ្វាក៏ដោយ ក៏ស្ថានភាពក្នុងប្រទេសក្នុងពេលនោះ(ប្រមាណជាឆ្នាំ ៧៨៧) មានសភាពអាប់អួរខ្លាំងណាស់ ព្រោះត្រូវបែកបាក់គ្នា ហើយស្ថិតក្រោមអំណាចបរទេសថែមទៀត ។

ការរំដោះប្រទេសជាតិអោយមានឥស្សរភាព និងបង្រួបបង្រួមអោយមានឯកភាពឡើងវិញជាស្នាព្រះហស្ថរបស់ព្រះបាទជ័យវរ្ម័នទី ២នេះឯង ។ សិលាចារឹកស្ដុកកក់ធំបានបញ្ជាក់ថាក្សត្រអង្គនេះបានយាងមកពីស្រុកជ្វា(33) ។ អ្នកប្រវត្តិសាស្រ្តបានប៉ាន់ស្មានថា ដែលព្រះបាទជ័យវរ្ម័នទី២អាចយាងត្រឡប់មកប្រទេសខ្មែរវិញ គឺដោយសារនៅពេលនោះរាជវង្សសៃលេន្ទ្របានចុះទន់ខ្សោយទៅហើយ ។ ចុះព្រះអង្គទៅប្រទេសជ្វានៅពេលណា ?

- រឿងនេះគេមិនអាចដឹងច្បាស់ឡើយ តែបើតាមការប៉ាន់ស្មានដដែលព្រះវង្សព្រះអង្គទំនងជាបានភៀសទៅបរទេសនៅពេលដែលមានភាពច្របូកច្របល់ក្នុងស្រុកដោយសារការបែងចែកទឹកដី ឬមួយត្រូវពួកជ្វាចាប់បង្ខំនាំទៅនៅគ្រាដែលចូលមកលុកលុយសម្ភុបុរ ។ បើតាមសិលាចារឹកព្រះបាទ (ស្លោកទី២)ព្រះបាទជ័យវរ្ម័នទី ២ត្រូវជាចៅមីងទូតរបស់ព្រះបាទបុស្ករាក្ស ដែលបានសោយរាជ្យនៅសម្ភុបុរនិង ត្រូវជាក្មួយរបស់ក្សត្រជយេន្ទ្រាធិបតិវរ្ម័នដែលគេមិនស្គាល់ប្រវត្តិ ។

ព្រះបាទជ័យវរ្ម័នទី ២បានយាងត្រឡប់មកពីប្រទេសជ្វាប្រហែលជា គ.ស.៨០០ ។ ពេលដំបូងព្រះអង្គយាងទៅគង់នៅ **ឥន្ទ្របុរ**ទំនងជាត្រង់ **បន្ទាយព្រៃនគរ** ស្រុកត្បូងឃ្មុំខេត្តកំពង់ចាម ។ គឺនៅទីនោះហើយដែលព្រះអង្គបានទទួលអោយព្រាហ្មណ៍ **សិវកៃវល្យ** ចូលធ្វើជារាជបុរោហិតរបស់ព្រះអង្គ ។ មុននឹងបានឡើងសោយរាជ្យ ព្រះអង្គត្រូវធ្វើការបង្រួបបង្រួមទឹកដីអោយបានមួយភាគសិនដូច្នេះហើយបានជាព្រះអង្គត្រូវផ្លាស់ប្តូររាជធានីញឹកញាប់ណាស់ ។ បន្ទាប់ពីឥន្ទ្របុរ ព្រះអង្គបានយាងទៅគង់នៅម្តុំខាងជើងបឹងទន្លេសាបនៅត្រង់ **កុតិ** (កន្លែងប្រាសាទបន្ទាយក្តី) រួចទៅនៅ **ហរិហរាល័យ** ក្នុងស្រុករលួសប្រមាណជា១៥គ.ម.ពីក្រុងសៀមរាប បន្ទាប់មកទៀតនៅ **អមរេន្ទ្របុរ** ដែលទំនងជាស្ថិតនៅត្រង់ទំនប់ខាងលិចនៃបារាយទឹកថ្លា ព្រោះនៅទីនោះគេឃើញមានប្រាសាទក្នុងរចនាបថ ខាងដើមសិល្បៈបុរេអង្គរតែមុនរចនាបថគូលែន ។ ចុងក្រោយបង្អស់ព្រះអង្គ យាងទៅគង់នៅលើភ្នំគូលែន (**មហេន្ទ្របព៌ត**)ហើយព្រាហ្មណ៍សិវកៃវល្យក៏និមន្តទៅជាមួយព្រះអង្គទៀត ។ គឺនៅលើកំពូលភ្នំគូលែននេះហើយ ដែលព្រះបាទជ័យវរ្ម័នទី២ ទ្រង់ប្រារព្ធធ្វើពិធីថ្មីមួយហៅថា "**ពិធីទេវរាជ**" ក្នុងបំណងធ្វើអោយប្រទេសខ្មែរ (កម្ពុជទេស) រួចពីចំណុះជ្វា ព្រមទាំងធ្វើអោយព្រះអង្គមានឋានៈជា **ចក្រវាតិន** (ស្តេចចក្រវាល) ។ គ្រានោះ ព្រះអង្គទ្រង់បញ្ជាអោយគេនិមន្តព្រាហ្មណ៍ម្នាក់ឈ្មោះ **ហិរណ្យ-ទាម** ដែលមានចំណេះវិជ្ជាយ៉ាងច្រើនខាងមន្តអាគមនៅស្រុក **ជនបទ** ។ ព្រាហ្មណ៍នេះបានធ្វើពិធីមួយតាមគម្ពីរ **វិនាសិខ** ហើយអភិសេកព្រះបាទជ័យវរ្ម័នទី២ (គ.ស.៨០២) អោយមាន ឋានៈជា **ទេវរាជ** (ស្តេចអាទិទេព) ពាក្យខ្មែរបុរាណហៅថា **កម្រតេងជគតតរាជ្យ** (ស្តេចដែលជាម្ចាស់នៃចក្រវាល) ។ ព្រាហ្មណ៍សិវកៃវល្យក៏បានរៀនពីព្រាហ្មណ៍ ហរិណ្យទាមនូវគម្ពីរបួន គឺ **វិនាសិខ-នយោត្តរសម្មោហនិងសិរច្ឆេទ**ព្រមទាំងរបៀបប្រារព្ធធ្វើពិធីទេវរាជទៀតផង ។ ព្រះរាជាព្រមទាំងព្រាហ្មណ៍ហរណ្យទាមបានធ្វើសច្ចាថាអំណើះតទៅមានតែសមាជិកគ្រួសារនៃព្រាហ្មណ៍សិវកៃវល្យទេដែលអាចប្រារព្ធធ្វើពិធីទេវរាជនេះបាន ។

តាមយោបល់លោក G.Coedès ថា ប្រសិនបើគេនឹកទៅដល់រឿងដែលឈ្មួញអារ៉ាប់ឈ្មោះស៊ូឡៃម៉ាន់ បាននិទានដោយមានបញ្ជាក់ពីការដែលជ្វាមកលុកលុយប្រទេសចេនឡា ដោយចាប់បានព្រះរាជាខ្មែរហើយកាត់ព្រះសិរផងនោះហើយ ដើម្បីអោយប្រទេសនេះរួចផុតពីអំណាចរបស់ជ្វាវិញគេអាច

សន្មតថាក្នុងពិធីលើភ្នំគូលែននោះ ប្រហែលជាមានធ្វើឧបកិច្ចផ្តាច់ព្រះសិរបដិមាជាតំណាងស្តេចជ្វាវង្ស សៃលេន្រ្ទ ស្របតាមគម្ពីរសិរច្ឆេទ(កាត់ក្បាល)ជាមិនខាន ។ ក្នុងពេលជាមួយគ្នានេះគឺអភិសេកសិវលិង្គ ដែលគេសន្មតថា បានមកពីព្រះឥស្វរតាមរយៈព្រាហ្មណ៍ ។ ធ្វើដូច្នេះ គេអាចចាត់ទុកថា **អាត្ម័នពិសិដ្ឋ** របស់ព្រះរាជាបានទៅសណ្ឋិតនៅក្នុងសិវលិង្គនោះ ដែលបានក្លាយជាតំណាងឬនិមិត្តរូបនៃទេវរាជ ។ បើនិយាយអោយងាយយល់គឺថាក្រោយពីធ្វើពិធីអភិសេកនេះហើយ ព្រះរាជាក៏ក្លាយទៅជាព្រះឥស្វរ បែងភាគ(មិនមែនគ្រាន់តែជាតំណាងទេ) ដែលមានអំណាចអាចគ្រប់គ្រងទៅលើសព្វសត្វ ។ ចាប់ពី ពេលនោះទៅបញ្ជារបស់ព្រះរាជាក៏គឺជាបញ្ជារបស់អាទិទេពនេះឯង ។ ការគោរពប្រតិបត្តិតាមបញ្ជានឹង នាំមកនូវកុសលផលបុណ្យដល់អ្នកដែលបាន ប្រព្រឹត្តអំពើនោះ ។

ដោយហេតុថា ព្រះឥស្វរមានលំនៅនៅលើ **ភ្នំកៃលាស** សិវលិង្គដែលជាតំណាងព្រះឥស្វរផងជា តំណាងព្រះរាជាផងក៏ត្រូវយកទៅតំកល់លើភ្នំដែរ ។ ប្រសិនបើគ្មានភ្នំធម្មជាតិទេ គេត្រូវកសាងប្រាសាទ ដែលមានយឿនច្រើនជាន់ អោយមានកំពស់ដូចភ្នំ ហើយដែលគេហៅថា **ប្រាសាទភ្នំ** temple-montagne (34) ។ ប្រាសាទភ្នំនេះត្រូវស្ថិតនៅចំកណ្តាលរាជធានី ដែលគេចាត់ទុកថា នៅចំស្នូលនៃចក្រវាលថែម ទៀត ។



*ព្រះបាទជ័យវរ្ម័នទី១ ប្រារព្ធពិធីទេវរាជលើភ្នំគូលែន គ.ស ៨០២* (រូបស្រង់ពីប្រជុំទស្សនាវដ្តី)

នៅលើភ្នំគូលែន គេសន្មតថាប្រាសាទ **ព្រះអារាមរោងចិន** ជាប្រាសាទភ្នំទី១កសាងដោយព្រះ បាទជ័យវរ្ម័នទី ២ ។ នៅទីនោះនៅសល់តែយឿន បីជាន់ធ្វើពីថ្មបាយក្រៀមបល្លង្កមួយនិងសិវលិង្គមួយ ដែលមានរាងពិសេស ។

នេះជាលើកទី១ក្នុងប្រវត្តិសាស្ត្រខ្មែរ ហើយដែលគេមានឯកសារជាក់លាក់ស្តីពីពិធីទេវរាជដែល ជាពិធីមួយថ្មី ។ គេតែងចោទសួរថា តើពិធីនេះមានដើមកំណើតមកពីណា ? - មកពីជ្វា ជាទីដែល ព្រះបាទ ជ័យវរ្ម័នទី ២បានស្នាក់នៅ នៅទីនោះឬយ៉ាងណា ? ប្រវត្តិសាស្ត្រនៃឥណ្ឌូនេស៊ីបានអោយ ដឹងថា គេបានរកឃើញសិលាចារឹកសំស្រ្កឹតមួយមានចុះកាលកំណត់គ. ស.៧៦០នៅភូមិភាគខាងកើតនៃ កោះជ្វា ។សិលាចារឹកនេះបាននិយាយពីក្សត្រជ្វាដែលគោរពបូជាលិង្គ **បុតិកេស្វរ**ដែលជាតំណាងទេវ រាជ (13) ។ចំនែកឯប្រវត្តិសាស្ត្រចាមក៏បានអោយដឹងថា នៅស. វ. ទី៤ព្រះបាទ **ភទ្រវរ្ម័ន** បានកសាង

ប្រាសាទមួយឧទ្ទិសចំពោះព្រះ**តទ្រេនស្វរ**ដែលគេឃើញក្សត្រនៅចេនឡាបានគោរពបូជានៅប្រាសាទវត្តភូដែលជាហេតុនាំអោយគេសន្និដ្ឋានថា **តទ្រេនស្វរ** នេះជាព្រះឥសូររួមរបស់ជនជាតិខ្មែរផងនិងជនជាតិចាមផងព្រោះពេលក្រោយៗមកទៀត ព្រះរាជានៅអង្គរទ្រង់នៅតែគោរពបូជា ដូចជាព្រះបាទយសោវរ្ម័នទី១ នៅប្រាសាទព្រះវិហារនិងព្រះបាទរាជេន្ទ្រវរ្ម័នទី២ នៅប្រាសាទប្រែរូប ។ នៅសម័យអាណាចក្រភ្នំ ព្រះរាជាមានឋានៈជាតំណាងព្រះឥសូរ ហើយតែងតែយាងឡើងលើភ្នំម៉ូតានដើម្បីគោរពបូជាចំពោះ ព្រះអង្គ ។ នៅសម័យចេនឡា សិលាចារឹកឆ្នាំ ៧១៣ របស់ព្រះនាងជយទេវី បាននិយាយចំពោះព្រះបាទជ័យវរ្ម័នទី១ ថា ជា "ក្សត្រដែលបានយ៉ាងទៅកាន់សិវបុរ" ឯសិលាចារឹក៨០៣ បាននិយាយថាព្រះបាទបុស្ករាក្ស (?)មានព្រះមរណនាមថា **ឥន្ទ្រលោក** ។

ទាំងនេះបង្ហាញអោយឃើញថា នៅភូមិភាគអាស៊ីអគ្នេយ៍យើងនេះ គ្រប់តែរដ្ឋដែលទទួលយកទស្សនៈសិវនិយមខាងរាជាធិបតេយ្យសុទ្ធតែមានការគោរពបូជាយ៉ាងផ្តេកផ្តួលចំពោះសិវលិង្គព្រមទាំងមានគំនិតរំលាយខ្លួនជាមួយទេវៈនេះថែមទៀត ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថាគំនិតទេវរាជនេះទំនងជាមានយូរណាស់មកហើយ ។ ព្រះបាទជ័យវរ្ម័នទី ២គ្រាន់តែបានធ្វើអោយលទ្ធិនេះមានលក្ខណៈច្បាស់លាស់ឡើងដោយបានទទួលឥទ្ធិពលពីជ្វា ប៉ុន្តែហេតុដែលគួរអោយកត់សំគាល់គឺ នៅឥណ្ឌូនេស៊ីក្តីនៅចាម្ប៉ាក្តី គេមិនឃើញមានប្រាសាទភ្នំដូចនៅស្រុកខ្មែរយើងទាល់តែសោះ ។ ដូច្នេះ យើងអាចចាត់ទុកថាប្រាសាទភ្នំជាស្នាដៃស្ថាបត្យកម្មនៃទេពកោសល្យខ្មែរហើយការវិវត្តន៍នៃប្រាសាទប្រភេទនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងដំណើរវិវត្តន៍នៃប្រវត្តិសាស្ត្រខ្មែរយើងនេះតែម្តង ។

គេមិនដឹងច្បាស់ថា ព្រះបាទជ័យវរ្ម័នទី ២គង់លើភ្នំគូលែនអស់រយៈពេលប៉ុន្មានឆ្នាំទេ ។ ទំនងជាការតាំងរាជធានីនៅលើកំពូលភ្នំដូច្នេះនាំអោយមានឧបសគ្គផ្សេងៗ ទើបព្រះអង្គយាងត្រឡប់ទៅគង់នៅហរិហរាល័យទៅវិញដោយនាំយកលិង្គទេវរាជទៅជាមួយផង ។ ព្រះបាទជ័យវរ្ម័នទី២ សោយទីវង្គតនៅហរិហរាល័យនៅឆ្នាំ៨៥០ ហើយទ្រង់បានទទួលមរណនាមថា **បរមេស្វរ** ។ នេះជាលើកទីមួយហើយដែលគេឃើញមានការប្រើប្រាស់មរណនាមយ៉ាងជាក់លាក់ចំពោះព្រះរាជា : នាមនេះបង្ហាញអោយដឹងថាដល់ពេលសោយទីវង្គតទៅព្រះរាជាយាងទៅគង់នៅស្ថានណាហើយជាមួយទេវអង្គណា ។ ចំពោះព្រះបាទជ័យវរ្ម័នទី២ ព្រះមរណនាម **បរមេស្វ** < **បរម** + **ឥស្វរ** បញ្ជាក់អោយឃើញច្បាស់ថាព្រះអង្គយាងទៅគង់ជាមួយព្រះឥសូរនេះឯង ។

ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាម **ជយវទ្ធនៈឬជ័យវរ្ម័នទី៣** បានសោយរាជ្យស្នងព្រះអង្គ ។ ក្សត្រអង្គនេះគង់នៅរាជធានីហរិហរាល័យតទៅទៀតរហូតដល់ គ.ស.៨៧៧ ។ ព្រះអង្គទ្រង់សព្វហឫទ័យនឹងការប្រមាញ់ដំរីណាស់ ទ្រង់បានកសាងប្រាសាទខ្លះនៅតំបន់អង្គរ ហើយលុះសោយទីវង្គតទៅ ទ្រង់បានទទួលមរណនាមថា **វិស្ណុលោក** ។

# ខ. រាជវង្សព្រះបាទឥន្ទ្រវរ្ម័នទី ១

## ១. ព្រះបាទឥន្ទ្រវរ្ម័នទី១ និងលទ្ធិបុគ្គលនិយម

ដោយព្រះបាទជ័យវរ្ម័នទី៣ ពុំមានបុត្រសោយរាជ្យស្នង ប្អូនជីដូនមួយរបស់ព្រះអង្គព្រះនាម ឥន្ទ្រវរ្ម័នទី១ ក៏បានទទួលរាជសម្បត្តិនៅពេលដែលព្រះអង្គសោយទីវង្គត ។ សិលាចារឹកព្រះគោបាន អោយដឹងថា ព្រះបាទឥន្ទ្រវរ្ម័នទី១ជាបុត្ររបស់ស្តេច **បឬថិវីន្ទ្រវរ្ម័ន** និងត្រូវជាចៅទួតតាមខ្សែមាតា របស់ស្តេច **នឫបតីន្ទ្រវរ្ម័ន**ដែលគេមិនដឹងច្បាស់ពីព្រះជីវប្រវត្តិ ។ អគ្គមហេសីរបស់ព្រះអង្គគឺព្រះនាង **ឥន្ទ្រទេវី** ជាក្សត្រីមានជាប់ពូជពង្សពីព្រះបាទបុស្ករាក្ស ។



*ប្រាសាទព្រះគោ (គ.ស ៨៧៩ )*

ក្រោយពីបានទទួលរាជសម្បត្តិនៅ គ.ស.៨៧៧ ហើយព្រះអង្គទ្រង់បានធ្វើសេចក្តីសច្ចាថា: “ក្នុង ប្រាំថ្ងៃទៀត ខ្ញុំនឹងចាប់ផ្តើមជីក ។ ល ។ ”(សិលាចារឹកព្រះគោ- ស្លោកទី៧) ។ សេចក្តីក្នុងសិលាចារឹក នេះបានដៅចំពោះការជីកបារាយ **ឥន្ទ្រតដាក**នៅខាងជើងរាជធានីដែលមានប្រវែង ៣០០០ម.ទទឹង ៨០០ម.និង ដាក់ទឹកបាន៦ លានម៉ែត្រត្រីគុណ(35) ។ ពិតមែនហើយថាការកសាងបារាយនេះធ្វើឡើង តាមតម្រូវការខាងសាសនា ប៉ុន្តែវាបានផ្តល់ប្រយោជន៍មួយយ៉ាងធំចំពោះកសិកម្មដែរ ។ នេះជាគំរូល្អ មួយដែលព្រះបាទឥន្ទ្រវរ្ម័ន ទ្រង់បានប្រទានចំពោះព្រះរាជាដែលសោយរាជ្យតៗពីព្រះអង្គ ។ យ៉ាងណា

មិញ បារាយឥន្ទ្រដាក់ នេះគេជីកអែបនឹងស្ទឹងរលួស ។ នៅរដូវវស្សា ទឹកភ្លៀងបានហូរចូលក្នុងបារាយ នោះ ។ នៅរដូវប្រាំង គេគ្រាន់តែជីកប្រឡាយកាត់ទំនប់ដែលព័ទ្ធជុំវិញបារាយ គេក៏អាចបង្ហូរទឹកចូល ក្នុងស្រែបានយ៉ាងស្រួល ។ នៅឆ្នាំ៨៧៩ ព្រះបាទឥន្ទ្រវរ្ម័នទ្រង់បានកសាងប្រាសាទ **ព្រះគោ** ដើម្បីឧទ្ទិស ថ្វាយចំពោះបុព្វបុរសរបស់ព្រះអង្គមានព្រះមាតាព្រះបិតាជីដូនជីតាខាងព្រះមាតាព្រះបាទជ័យវរ្ម័នទី២ និងព្រះអគ្គមហេសី ។ ប្រាសាទនេះមានរាងជាប្រាង្គឥដ្ឋ៦ តំរៀបជាពីរជួរមុខក្រោយហើយស្ថិតនៅលើ ឃឿនតែមួយ ។ បុព្វបុរសទាំងនោះមាន ព្រះនាមជាទេវនាមហើយមានរូបតំណាងជាសិវលិង្គចំពោះ បុព្វបុរសប្រុសនិងរូបទេវីចំពោះបុព្វបុរសស្រីៈ

**ប្រាសាទព្រះគោ (គ.ស.៨៧៩)**

| | | |
|---|---|---|
| **ស្រីបឬថិវីន្ទ្រេស្វរ** | = | ព្រះបិតា |
| **ស្រីបឬថិវីន្ទ្រទេវី** | = | ព្រះមាតា |
| **ស្រីបរមេស្វរ** | = | ព្រះបាទជ័យវរ្ម័នទី ២ |
| **ស្រីធរណាន្ទ្រទេវី** | = | អគ្គមហេសីព្រះបាទជ័យវរ្ម័នទី ២ |
| **ស្រីរុទ្រេស្វរ** | = | ជីតាខាងព្រះមាតា |
| ? | = | ជីដូនខាងព្រះមាតា។ |

នេះជាលើកដំបូងក្នុងប្រវត្តិសាស្ត្រខ្មែរដែលគេមានឯកសារជាក់លាក់ពីការគោរពបូជាបុព្វបុរស របស់ព្រះរាជាដែលត្រូវលើកតំកើងអោយមានឋានៈស្មើនឹងទេវ-ទេវីដែរ ។ ត្រង់នេះអ្នកសិក្សាតែង ចោទសួរថា តើលទ្ធិថ្មីនេះដែលគេហៅថា "**លទ្ធិបុគ្គលនិយម**" ជាមែកធាងមួយរបស់លទ្ធិទេវរាជ មួយ ផ្ទុយទៅវិញលទ្ធិទេវរាជគ្រាន់តែជាទិដ្ឋភាពពិសេសមួយរបស់លទ្ធិបុគ្គលនិយម ? តែទោះជា យ៉ាងណាក៏ដោយ ក៏គួរគប្បីជ្រាបថាទំលាប់គោរពបូជាបុព្វបុរសនេះខ្មែរយើងធ្លាប់មានជាយូរលង់ ណាស់មក ហើយ ។ សព្វថ្ងៃនេះខ្មែរយើងនៅតែបន្តការគោរពបូជានេះតទៅទៀត ហើយដែលយើង អាចមើលឃើញជាពិសេសក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនេះឯង ។

ចុងក្រោយបង្អស់នៅឆ្នាំ ៨៨១ ព្រះបាទ ឥន្ទ្រវរ្ម័នទី១ ទ្រង់បានកសាងប្រាសាទ **បាគង** ដែលជា ប្រាសាទភ្នំទី១ សាងពីថ្មភក់មានទ្រង់ទ្រាយច្បាស់លាស់គឺមានឃឿន៣ ជាន់សំរាប់តំកល់លិង្គទេវរាជ ឈ្មោះ **ឥន្ទ្រេស្វរ** ( ឥន្ទ្រ = ឈ្មោះព្រះរាជា + ឥស្វរ = ព្រះឥសូរ) ។

ក្នុងរជ្ជកាលរបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ ប្រទេសខ្មែរទំនងជាមានសន្តិភាពបរិបូណ៌ ។ អំណាច របស់ព្រះអង្គបានលាតសន្ធឹងរហូតដល់តំបន់មាត់ជ្រូកនៅខាងត្បូង ជាទីដែលព្រះអង្គបានសាងប្រាសាទ មួយឧទ្ទិសចំពោះព្រះសិវនៅលើភ្នំបាយ៉ង់ ។ នៅផ្នែកខាងលើ អំណាចគ្រប់គ្រងរបស់ព្រះអង្គបានទៅ

ដល់តំបន់ពាយព្យអ៊ូបុន ដែលនៅទីនោះគេបានរកឃើញសិលាចារឹកពុទ្ធសាសនាមួយចារនៅគ. ស. ៨៨៦ ហើយនិយាយបញ្ជាក់ថាព្រះអង្គជាស្តេចសោយរាជ្យ ។ ក្នុងវិស័យនយោបាយក្រៅប្រទេសវិញ ខ្មែរមានចំណងទូតជាមួយប្រទេសចិន ប្រទេសចាម្ប៉ានិងជ្វា ។

ព្រះបាទឥន្ទ្រវរ្ម័នទី១ ទ្រង់បានសោយទីវង្គតនៅគ. ស. ៨៨៩ ហើយបានទទួលមរណនាមថា **ឥសូរលោក** ។

## ២. ព្រះបាទយសោវរ្ម័នទី១ និងការកសាងក្រុងអង្គរ

បុត្ររបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ នាម **យសោវធ៌ន** បានឡើងសោយរាជ្យស្នងមាននាមថា **យសោវរ្ម័នទី១** ។ សិលាចារឹកបានបញ្ជាក់ថា ព្រះមាតានាមឥន្ទ្រទេវីមានជាប់ខ្សែស្រឡាយពីរាជវង្ស នៅវ្យាធបុរ សម្ភុបុរ និងអនិន្ទិតបុរ ។ ព្រះគ្រូរបស់ព្រះអង្គគឺ ព្រាហ្មណ៍ **វាមសិវ** ជាប់ពូជពង្សមកពីគ្រួសារព្រាហ្មណ៍សិវកៃវល្យ ដែលបានទទួលភារៈប្រារព្ធធ្វើពិធីទេវរាជតៗមក ។

លុះបានទទួលរាជសម្បត្តិភ្លាម ព្រះបាទយសោវរ្ម័នទី១ទ្រង់បានកសាងនៅគ្រប់ខេត្តខណ្ឌនូវអាស្រមចំនួន១០០ (**យសោធរាស្រម**) ហើយដែលសព្វថ្ងៃគេអាចស្គាល់កន្លែងបានតែជាង១០ប៉ុណ្ណោះ ។ នៅកន្លែងនីមួយៗគេបានរកឃើញសិលាចារឹកមួយផ្ទាំងដែលមានសេចក្តីប្រហាក់ប្រហែលគ្នា គឺបាន រៀបរាប់ពីពង្សាវលីរបស់ព្រះបាទយសោវរ្ម័ននិងបានសរសេរពីគុណសម្បត្តិរបស់ព្រះអង្គ ។

នៅគ. ស. ៨៩៣ព្រះបាទយសោវរ្ម័នទី១ទ្រង់បានសាងនៅកណ្តាលបារាយណ៍ឥន្ទ្រតាដាកនូវប្រាសាទ **លលៃ** ដែលមានប្រាង្គឥដ្ឋ៤ តំរៀបជាពីរជួរមុខក្រោយសំរាប់ឧទ្ទិសចំពោះព្រះមាតាបិតា និងជីដូនជីតាខាងព្រះមាតារបស់ព្រះអង្គ ។

ព្រះបាទយសោវរ្ម័នទី១ពុំបានគង់នៅហរិហរាល័យអោយបានយូរទេ ។ សិលាចារឹកស្តុកកក់ធំប្រាប់ថាៈ "**ព្រះបរមសិវលោក**"បានសាងក្រុង **យសោធរបុរ** ហើយទ្រង់បាននាំយកទេវរាជពីហរិហរាល័យទៅតំកល់នៅក្រុងថ្មីនេះ ។ បន្ទាប់មកព្រះបរមសិវលោកទ្រង់បានកសាង **ភ្នំកណ្តាល** ។ ចំណែកឯព្រះគ្រូវាមសិវបានសាងព្រះទេវលិង្គនៅចំកណ្តាល ។ ក្រោយពីការសិក្សាស្រាវជ្រាវអស់ពេលយ៉ាងយូរមានទាំងការពិនិត្យលើយន្តហោះផង(ដោយលោក victor Goloubew)ទើបគេបានដឹងថាក្រុង **យសោធរបុរ** នោះត្រូវនឹងក្រុងមួយដែលមានកំពែងដីព័ទ្ធជុំវិញ (សព្វនៅសល់ស្នាមខ្លះនៅទិសខាងលិចនិងខាងត្បូង ) ហើយដែលមានភ្នំបាខែងនៅចំកណ្តាល (គឺភ្នំកណ្តាលក្នុងសិលាចារឹក)សំរាប់តំកល់លិង្គ **យសោធរេស្វរ**(គ. ស. ៨៩៣) ។ ចំពោះបុព្វហេតុដែលបណ្តាលអោយព្រះបាទយសោវរ្ម័នទី១លើករាជធានី ចេញពីហរិហរាល័យ មានប្រវត្តិវិទូខ្លះយល់ថានៅទីនោះ មានប្រាសាទនិងសំនង់ផ្សេងៗទៀត

ច្រើនណាស់ទៅហើយ ជាហេតុនាំអោយចង្អៀតចង្អល់មិនអាចធ្វើការកសាងផ្សេងៗទៀតបានឡើយ ។ យោបល់នេះឃើញថាសមហេតុសមផលដែរ ព្រោះបើតាមសង្កេតទៅ ព្រះរាជាដែលសោយរាជ្យៗតគ្នារមែងតែងតែចង់បង្ហាញមហិទ្ធិរិទ្ធិរបស់ព្រះអង្គជាស្តេចអាទិទេព ដោយការកសាងធំៗហើយច្រើនជាងព្រះរាជាមុនជានិច្ច ។ ប្រាសាទភ្នំដែលកសាងឡើងហើយ ប្រើបានសំរាប់តែព្រះរាជាមួយអង្គទេព្រោះដល់ពេលចូលទីវង្គតទៅ ប្រាសាទនោះក្លាយទៅជាផ្នូររបស់ព្រះអង្គ ហើយព្រះរាជាដែលស្នងរាជ្យត្រូវតែខំកសាងប្រាសាទភ្នំមួយថ្មីទៀត(36) ។

ក្នុងការកសាងរាជធានីថ្មីនេះ ព្រះបាទយសោវរ្ម័នទី១ទ្រង់បានកសាងបារាយមួយនៅទិសឦសាន ហៅថា **យសោធរតដាក** មានប្រវែង៧គ.ម. និងទទឹង១.៨គ.ម. ។ នៅលើច្រាំងខាងត្បូងនៃបារាយនេះ (បារាយខាងកើត)ព្រះអង្គទ្រង់អោយកសាងអាស្រមជាច្រើនសំរាប់គណៈសាសនាផ្សេងៗ :

- **ព្រាហ្មណាស្រម** : សំរាប់អ្នកកាន់សាសនាព្រះឥសូរ
- **វៃស្នវាស្រម** : សំរាប់អ្នកកាន់សាសនាព្រះវិស្ណុ
- **សៅគតាស្រម** : សំរាប់អ្នកកាន់សាសនាព្រះពុទ្ធ (?)

ក្នុងរាជ្យរបស់ព្រះអង្គ គេបានផ្តើមការកសាងប្រាសាទពីរទៀតឧទ្ទិសចំពោះព្រះឥសូរ គឺប្រាសាទ **សិខរីស្វរ** នៅលើភ្នំព្រះវិហារនិងប្រាសាទ **តន្រ្ទេស្វរ** នៅសិវបុរ(ភ្នំសណ្តក) ។ ចំណែកឯនៅលើភ្នំបូក និងភ្នំក្រោមព្រះអង្គបានសាងប្រាសាទមានប្រាង្គ ៣សំរាប់ឧទ្ទិសចំពោះត្រីមូ៌តិ(ព្រះព្រហ្ម -ព្រះវិស្ណុ-ព្រះឥសូរ) ។

ព្រះបាទយសោវរ្ម័នទី ១ជាព្រះរាជាដែលគេបានដឹងលឺច្រើនដោយសារតែព្រះអង្គជាស្ថាបនិកទី១នៃក្រុងអង្គរ(យសោធរបុរ)ដែលស្ថិតនៅជារាជធានីរបស់ខ្មែរអស់រយៈពេល៦សតវត្ស ។ ប៉ុន្តែប្រវត្តិនយោបាយក្នុងរជ្ជកាលរបស់ព្រះអង្គគេពុំបានដឹងច្បាស់ឡើយ ។ តាមប្រភពសិលាចារឹកនៅស.វ.ទី១២ គេដឹងថាខ្មែរបានលើកទ័ពទៅវាយប្រទេសចាម្ប៉ា ។ ចំពោះអំណាចគ្រប់គ្រងរបស់ខ្មែរក្នុងពេលនោះ គេអាចដឹងបានដោយវត្តមាននៃសិលាចារឹករបស់ព្រះបាទយសោយវរ្ម័នទី ១:ខាងជើងទល់នឹងប្រទេសឡាវ ផ្នែកខាងក្រោម តាមមាត់សមុទ្រចាប់ពីតំបន់ចន្ទបូររហូតដល់ខេត្តពាម ។ ប៉ុន្តែបើយោលតាមពត៌មាន ដែលសិលាចារឹកសម័យក្រោយមក ឃើញថាព្រំដែនខ្មែរនៅពេលនោះទូលំទូលាយជាងនេះ ឆ្ងាយណាស់ ។ យ៉ាងណាមិញ សិលាចារឹករបស់ព្រះបាទរាជេន្ទ្រវរ្ម័ន(ក្មួយរបស់ព្រះអង្គ)នៅស.វ.ទី១០បានបញ្ជាក់ថាប្រទេសខ្មែរខាងលិចទល់នឹងដែនសូត្សកម្រាតាស(ប្រទេសភូមា)ខាងត្បូងទល់នឹងសមុទ្រខាងកើតទល់នឹងចាម្ប៉ា ខាងជើងទល់នឹងប្រទេសចិន គឺតំបន់ណាននាវ ដែលឯកសារចិនមួយបានបញ្ជាក់យ៉ាងហ្មឹងម៉ាត់ថាមានព្រំប្រទល់ជាប់នឹងប្រទេសខ្មែរនៅក្នុងពាក់កណ្តាលទី២នៃស.វ.ទី៩ មែន ។ សិលា

ចារឹកផ្សេងទៀតបាននិយាយពី "ជោគជ័យក្នុងចម្បាំងជើងទឹកទៅលើពួកទ័ពដែលប្រើសំពៅមានក្តោងពណ៌ស "តែគេមិនដឹងច្បាស់ថាពួកនេះជាពួកចាមឬពួកជ្វាទេ ។

ព្រះបាទយសោវរ្ម័នទី១ទ្រង់ចូលទីវង្គតនៅគ.ស.៩០០ ហើយមានមរណនាមថា **បរមសិវលោក** ។ បុត្ររបស់ព្រះអង្គទាំងពីរបានឡើងសោយរាជ្យស្នងជាបន្តបន្ទាប់គ្នា។



ប្រាសាទបក្សីចាំក្រុង

បុត្រច្បងព្រះនាម **ហសិវរ្ម័នទី១** បាន សោយរាជ្យពីគ.ស.៩០០ដល់ក្រោយ៩២២ ។ ព្រះអង្គបានសាងប្រាសាទភ្នំតូចមួយនៅក្បែរជើងភ្នំបាខែងគឺ **ប្រាសាទបក្សីចាំក្រុង** ។ ព្រះអង្គទ្រង់មានមរណនាមថា **រុទ្រលោក** ។ ព្រះអនុជព្រះនាម **ឦសានវរ្ម័នទី២** បានឡើងសោយរាជ្យនៅគ.ស.៩២៥ ហើយលុះចូលទីវង្គតទៅបានទទួលមរណនាមថា **បរមរុទ្រលោក** ។

## ៣. ព្រះបាទជយវរ្ម័នទី៤និងការលើករាជធានីទៅកោះកេរ្តិ៍

សិលាចារឹកស្តុកកក់ធំអោយដឹងថាចាប់ពីគ.ស.៩២១ទៅព្រះបាទ **ជយវរ្ម័នទី៤** ដែលជាប្អូនថ្លៃរបស់ព្រះបាទយសោវរ្ម័នទី ១បានយាងចេញពីយសោធរបុរដើម្បីទៅគង់នៅឯ **ឆោកគគ្យ៉រ** (កោះកេរ្តិ៍នៅចម្ងាយ៧០គ.ម.ទិសឦសានក្រុងអង្គរ) ហើយថែមទាំងនាំយកទេវរាជទៅជាមួយផង ។ ត្រង់នេះប្រវត្តិវិទូអាចសន្និដ្ឋានបានថាជយវរ្ម័នទី៤ដែលរៀបរាជាភិសេកជាមួយនឹងនាង **ជយទេវី** (ប្អូនស្រី

របស់យសោវរ្ម័នទី១)បានជ្រែករាជ្យពីក្មួយរបស់ព្រះអង្គ ។ សិលាចារឹកប្រាសាទនាងខ្មៅអោយដឹងថា ព្រះបាទជយវរ្ម័នទី៤បានឡើងសោយរាជ្យនៅ គ.ស.៩២៨ដែលប្រហែលជាការកំណត់នៃមរណកាលរបស់ព្រះបាទឦសានវរ្ម័នទី២ ព្រោះចាប់ពីពេលនោះហើយដែលឪពុកមារបស់ព្រះអង្គមានឋានៈជាព្រះរាជាពេញលក្ខណៈ ។

ដើម្បីអោយប្រជារាស្ត្រទទួលស្គាល់ព្រះអង្គថាជាស្តេចមានមហិទ្ធិរិទ្ធិ ព្រះបាទជ័យវរ្ម័នទី៤ទ្រង់បានខិតខំកសាងសមិទ្ធិដែលសុទ្ធតែមានលក្ខណៈធំសម្បើម ហើយប្រកបដោយចលនាទៀតផង ។ ក្នុងរាជធានីថ្មីនេះ ព្រះអង្គបានសាងប្រាសាទភ្នំមួយមានឃឿន៧ជាន់កំពស់ ៣៥ម. សំរាប់តំកល់លិង្គ **ត្រិភុវនេស្វរ** គឺ **ប្រាសាទធំ** ដែលបានកសាងនៅប្រមាណគ.ស.៩៣១ ។ ក្រៅពីនេះព្រះអង្គបានសាងប្រាសាទជាច្រើនទៀតព្រមទាំងបារាយមួយគឺ បារាយ **រ៉ាហាល់** ។

ព្រះបាទជ័យវរ្ម័នទី៤ចូលទិវង្គតនៅគ.ស.៩៤១ ។ បុត្រព្រះអង្គនាម **ហសិវរ្ម័នទី២** បានឡើងស្នងរាជ្យតែបានតែ២ឬ ៣ ឆ្នាំក៏សោយទិវង្គតទៅ ហើយបានទទួលមរណនាមថា **ព្រហ្មលោក** ។

## ៤. រាជេន្ទ្រវរ្ម័នទី ២និងការវិលត្រឡប់មកយសោធរបុរវិញ

ប្អូនស្រីរបស់ព្រះបាទយសោវរ្ម័នទី១ មួយអង្គទៀតនាម **មហេន្ទ្រទេវី** បានរៀបរាជាភិសេកជាមួយស្តេច **មហេន្ទ្រវរ្ម័ន** ហើយមានបុត្រឈ្មោះ **រាជេន្ទ្រវរ្ម័ន** ។ ព្រះអង្គបានឡើងសោយរាជ្យសម្បត្តិពីព្រះបាទហសិវរ្ម័នទី ២តែព្រះអង្គមិនគង់នៅកោះកេរ្តិ៍តទៅទៀតទេ ព្រះអង្គលើករាជធានីត្រឡប់មកយសោធរបុរវិញដោយនាំយកទេវរាជមកជាមួយផង ។ គួរគប្បីបញ្ជាក់ថាស្តេចមហេន្ទ្រវរ្ម័នជាស្តេចសោយរាជ្យនៅភវបុរ ជារាជធានីចេនឡាបានតាំងជារដ្ឋឯករាជ្យ ក្រោយមរណកាលរបស់ព្រះបាទជ័យវរ្ម័នទី១ ។ បើដូច្នេះ ព្រះបាទរាជេន្ទ្រវរ្ម័ន ត្រូវមានអំណាចគ្រប់គ្រងធំទូលាយជាងព្រះរាជាមុនៗដោយបានទទួលមរតកពីបិតា គឺទឹកដីភវបុរផងនិងមត៌កខាងមាតាចក្រភពអង្គរនេះផង ។

នៅគ.ស.៩៥២ព្រះអង្គបានកសាងនៅកណ្តាលយសោធរតដាកនូវប្រាសាទ **មេបុណ្យខាងកើត** ដើម្បីឧទ្ទិសថ្វាយចំពោះព្រះមាតាបិតា ចំពោះបុព្វបុរសផ្សេងៗទៀត និងចំពោះសិវលិង្គ **រាជេន្ទ្រស្វរ** (នៅប្រាង្គកណ្តាលក្នុងចំណោមប្រាង្គទាំង៥តំរៀបដូចមុខអាប៉ោង) ។ នៅ គ.ស.៩៦១ព្រះអង្គបានសាងប្រាសាទ **ប្រែរូប** នៅខាងត្បូងយសោធរតដាក ។ នេះជាប្រាសាទភ្នំទី២របស់ព្រះអង្គ មានប្រាង្គ៥ដូចនៅមេបុណ្យខាងកើត ។ នៅប្រាង្គកណ្តាលមានតំកល់លិង្គ **រាជេន្ទ្រភទ្រេស្វរ** (ភទ្រេស្វរជាព្រះឥសូរដែលគេគោរពតាំងពីសម័យចេនឡាដើម) ។ នៅក្នុងប្រាង្គទិសឦសានមានតំកល់លិង្គ **រាជេន្ទ្រវម៌េស្វរ** ជាលិង្គទេវរាជ ឯប្រាង្គឯទៀតគឺឧទ្ទិសចំពោះព្រះញាតិព្រះអង្គ ។ អ្នកស្រាវជ្រាវតែងមានចម្ងល់ថា ចុះហេតុអ្វីបានជាព្រះបាទរាជេន្ទ្រវរ្ម័ន បានសាងប្រាសាទភ្នំដល់ទៅពីរដែលមានទ្រង់ទ្រាយដូចគ្នា ។

ចំពោះរឿងនេះ គេយល់ថាស្ថានភាពរបស់ប្រាសាទមេបុណ្យនៅកណ្តាលបារាយទំនងជាឧបសគ្គមួយក្នុងការប្រារព្ធធ្វើពិធីសាសនាផ្សេងៗ ទើបព្រះអង្គសាងប្រាសាទទី២នេះឡើង ។

ក្រៅពីប្រាសាទទាំងពីរខាងលើនិងការផ្តើមកសាងប្រាសាទ **ភិមានអាកាស** នៅក្នុងរជ្ជកាលរបស់ព្រះបាទរាជេន្ទ្រវរ្ម័ននៅមានការកសាងផ្សេងទៀតដោយពួកព្រាហ្មណ៍ឬពួកមន្ត្រីជាន់ខ្ពស់ ។ ពួកនេះទំនងជាឆ្លៀតឱកាសដែលព្រះរាជាមានវ័យនៅក្មេង ដើម្បីប្រើឥទ្ធិពលរបស់ខ្លួន ហើយគេបានសង្កេតឃើញថា នយោបាយបែបនេះនៅតែមានអនុវត្តតទៅទៀតក្នុងរជ្ជកាលព្រះរាជាក្រោយដោយមកពីហេតុដូចគ្នា ។ ក្នុងបណ្តាវរជនទាំងនោះ វរជនដែលមានឥទ្ធិពលជាងគេគឺ **រាជកុលមហាមន្ត្រី** ដែលទំនងជារាជានុសិទ្ធឬរដ្ឋមន្ត្រីទី១ព្រាហ្មណ៍ **សិវាចារ្យ**ជាហោតរ **កវិន្ទ្រារិមថន**ជាស្ថាបត្យករកសាងរាជវាំង និងប្រាសាទមេបុណ្យខាងកើត និងព្រាហ្មណ៍ **យជ្ញវរាហៈ** ព្រះរាជគ្រូ ។ នៅគ.ស.៩៤៦ កវីន្ទ្រា-រីមថន បានកសាងប្រាសាទ **បាតជុំ**ដើម្បីឧទ្ទិសថ្វាយចំពោះព្រះពុទ្ធ ព្រះវជ្របាណិ(ពោធិសត្វ១អង្គក្នុងពុទ្ធសាសនាមហាយាន) និងព្រះនាងប្រជ្ញាបារមិតា (ទេព្ធស្រី) ។

ក្នុងវិស័យសឹកសង្គ្រាមគេដឹងថានៅគ.ស.៩៤៥-៩៤៦ព្រះបាទរាជេន្ទ្រវរ្ម័នបានលើកទ័ពទៅវាយចាមហើយបាននាំមកវិញនូវរូបដិមាធ្វើពីមាសតំកល់ក្នុងប្រាសាទពោនគរនៅកៅឋារៈ(ញ៉ាត្រាង) ។

នៅគ.ស.៩៦៧ព្រះគ្រូយជ្ញវរាហៈបានសាងប្រាសាទ **បន្ទាយស្រី(ត្រិភូវនមហេស្វរ)**ដែលស្ថិតនៅខាងជើងក្រុងយសោធរបុរ ។

នៅឆ្នាំក្រោយ (គ.ស.៩៦៨)ព្រះបាទរាជេន្ទ្រវរ្ម័នបានចូលទីវង្គតហើយបានទទួលមរណនាមថា **សិវលោក** ។ បុត្ររបស់ព្រះអង្គគឺជ័យវរ្ម័នទី៥បានឡើងសោយរាជ្យស្នងនៅពេលដែលព្រះអង្គមានវ័យនៅក្មេងណាស់នៅឡើយព្រោះដល់គ.ស.៩៧៤ទើបព្រះអង្គបានបញ្ចប់ការអប់រំជាមួយព្រះគ្រូ ។ សមិទ្ធិសំខាន់ៗរបស់ព្រះអង្គគឺការកសាងក្រុងថ្មីហៅថា **ជយេន្ទ្រនគរី**ដែលមានភ្នំ **ហេមគិរី**នៅចំកណ្តាល ហើយដែលតាមការប៉ាន់ស្មាន គេថាត្រូវនឹងប្រាសាទភ្នំ **តាកែវ** ។

គួរកត់សំគាល់ថាព្រះរាជានិងពួកមន្ត្រីជាន់ខ្ពស់សុទ្ធតែកាន់សាសនាព្រះឥសូរ ។ ប៉ុន្តែក្នុងរជ្ជកាលនេះក៏ដូចជាក្នុងរជ្ជកាលមុនៗព្រះពុទ្ធសាសនាក៏បានគេគោរពបូជាដែរ ។ សិលាចារឹកវត្តសីធរជាសក្ខីភាពយ៉ាងសំខាន់មួយទៀតនៃអត្ថិភាពលទ្ធិពុទ្ធសាសនាមហាយាននៅស្រុកខ្មែរតពីសិលាចារឹកប្រាសាទតាគាមរៀងរហូតមក ។

ព្រះបាទជយវរ្ម័នទី៥សោយទីវង្គតនៅគ.ស.១០០១ ហើយមានមរណនាមថា **បរមវីរលោក** ។ ក្មួយរបស់ព្រះអង្គនាម **ឧទយាទិត្យវរ្ម័នទី១** ឡើងស្នងរាជ្យបានតែប៉ុន្មានខែក៏សោយទីវង្គតទៅទៀត (១០០១) ។

## គ. រាជវង្សព្រះបាទសូរ្យវរ្ម័នទី១

### ១. ព្រះបាទសូរ្យវរ្ម័នទី១

ក្រោយពីព្រះបាទឧទយាទិត្យវរ្ម័នទី១សោយទីវង្គតទៅ សិលាចារឹកនៅស.វ.ទី១១បានអោយដឹងថា មានស្តេចពីរអង្គប្រណាំងប្រជែងគ្នាក្នុងការដណ្តើមយករាជសម្បត្តិសោយ : មួយអង្គនាម **ជយវីរវរ្ម័ន** ដែលគេមិនស្គាល់ប្រវត្តិច្បាស់បានឡើងសោយរាជ្យនៅអង្គរ១០០២ដល់១០០៦មួយអង្គទៀតនាម **សូរ្យវរ្ម័ន** បានតាំងនៅតំបន់ខាងកើត(សំបូរក្រចេះនិងកំពង់ធំ) ។ នៅចន្លោះឆ្នាំ១០០៥និង១០០៧សូរ្យវរ្ម័ន បានលើកទ័ពចូលវាយអង្គរហើយបានទទួលជោគជ័យជាស្ថាពរនៅឆ្នាំ១០១០ប៉ុន្តែក្នុងសិលាចារឹករបស់ព្រះអង្គក្រោយៗមកទៀត ព្រះអង្គទ្រង់ចាត់ទុកថាព្រះអង្គបានឡើងសោយរាជ្យតាំងពីឆ្នាំ១០០២គឺតំណាលគ្នានឹងជយវីរវរ្ម័នម្ល៉េះ ។

ព្រះបាទសូរ្យវរ្ម័ន ទ្រង់បានបញ្ជាក់ក្នុងសិលាចារឹកថា ព្រះអង្គជាប់ញាតិខាងមាតានៃព្រះបាទឥន្ទ្រវរ្ម័នទី១ និងជាប់ញាតិទៅនឹងបុត្រយសោវរ្ម័នទី១ តាមរយៈអគ្គមហេសីរបស់ព្រះអង្គគឺព្រះនាងវីរលក្ស្មី ។

កាលប្បវត្តិ (chronique) ភាសាបាលីក្នុងស.វ.ទី១៥ បានចែងថា **សុជិតរាជ** ជាស្តេចគ្រប់គ្រងដែនដី Ligor មួយអង្គកាន់ព្រះពុទ្ធសាសនា ។ ស្តេចនេះបានមកចងស្ពានមេត្រីអភិសេកនឹងក្សត្រីខ្មែរមួយអង្គជាអគ្គមហេសីនៅជំនាន់ជាងពាក់កណ្តាលស.វ.ទី១០ ។ ក្សត្រីនេះជារាជវង្សឥន្ទ្រវរ្ម័នទី១ ។ បុត្រានៃសុជិតរាជនិងក្សត្រីខ្មែរនេះមាននាមថាសូរ្យវរ្ម័ន(37) ។ បើយោងតាមឯកសារនេះឃើញថាសូរ្យវរ្ម័នមានបិតាជាជ្វា ឯមាតាជាខ្មែរ ។ ប៉ុន្តែមានមតិខ្លះទៀតយល់ថាព្រះអង្គជារាជវង្សខ្មែរសុទ្ធសាធនៃជំនាន់អាណាចក្រភ្នំ ដែលបានភៀសទៅបរទេសនៅពេលដែលទ័ពចេនឡាចូលវាយលុក ។

ព្រះបាទសូរ្យវរ្ម័នជាព្រះរាជាទី១នៃអង្គរដែលកាន់ពុទ្ធសាសនាមហាយាន ។ ដូច្នេះ ព្រះអង្គទំនងជាយាងមកពី Ligor (នគរស្រីធម្មរាជ)មែន ព្រោះនៅទីនោះគេនិយមសាសនានេះខ្លាំងណាស់ ។ មរណនាមរបស់ព្រះអង្គ(**និព្វានបទ**) ជាសក្ខីភាពមួយស្រាប់ ។ ប៉ុន្តែទោះបីយ៉ាងហ្នឹងក៏ដោយ ក៏ការបូជាគោរពចំពោះទេវរាជនៅតែប្រព្រឹត្តជាបន្តទៅទៀត ។ នៅពេលឡើងសោយរាជ្យហើយនៅគ.ស.១០១១ព្រះអង្គតម្រូវអោយនាម៉ឺនសព្វមុខមន្ត្រីធ្វើសច្ចាប្រណិធានថាស្មោះត្រង់នឹងព្រះអង្គ ។ អត្ថបទនៃសេចក្តីសច្ចានេះមាននៅក្លោងទ្វារចូលទៅរាជវាំង ។

សិលាចារឹកខ្មែរនៅសាលសួងក្នុងដីសៀមសព្វថ្ងៃ (១០២២-១០២៥) បានអោយដឹងថាក្នុងរជ្ជ-កាលរបស់ព្រះអង្គ ពួកកាន់សាសនាព្រាហ្មណ៍និងពួកកាន់ពុទ្ធសាសនានៃយានទាំងពីរ បានរួមរស់សុខសាន្តជាមួយគ្នានៅតំបន់ល្វោ(លពបុរី)(36) ។

ក្នុងវិស័យសំណង់ ព្រះបាទសូរ្យវរ្ម័នទំនងជាបានស្ថាបនាបង្ហើយប្រាសាទភិមានាកាស ប្រាសាទតាកែវ និងគោបុរនៃរាជវាំង ។ ក្រៅពីនេះ ព្រះអង្គបានក៏សាងប្រាសាទភ្នំជីសូរ ផ្នែកខ្លះនៃប្រាសាទព្រះវិហារ និង **ព្រះខាន់កំពង់ស្វាយ** ។

ក្នុងវិស័យនយោបាយក្រៅប្រទេស ខ្មែរបានធ្វើការពង្រីកទឹកដី ឆ្ពោះទៅទិសខាងលិច ។ ព្រឹត្តិការណ៍ទាំងនេះ កាលប្បវត្តិជាភាសាបាលីនៅសៀងម៉ៃ បានកត់ត្រាទុកដូចជា **ចាមទេវីវង្ស** (ចងក្រងនៅស.វ.ទី១៥) **ជិនកាលមាលី** (គ.ស.១៥១៦)និង **មូលសាសន** ។ ផ្ទៀតឱកាសដែលស្តេចមននៅ **ហរិបុញ្ជ័យ(អន្ត្រាសតក)** និងស្តេចមននៅល្វោ ( **ឧទ្ធិត្ត**)ច្បាំងគ្នា មានស្តេចមួយអង្គយាងមកពី **សិរិធម្មនគរ**(Ligor) ព្រះនាមសុជិតបានលើកទ័ពជើងទឹកយ៉ាងសម្បើមមកឡោមព័ទ្ធក្រុងល្វោ ។ ដោយមានអន្តរាគមន៍របស់ស្តេចអង្គនេះ ស្តេចមនទាំងពីរបានភៀសខ្លួនឆ្ពោះទៅទិសហរិបុញ្ជ័យ ។ ក្រុងល្វោក៏បានទៅស្តេចសុជិត ។ ក្រោយមកទៀតបុត្ររបស់ព្រះអង្គ (?)នាម **កម្ពោជរាជ** លើកទ័ពទៅវាយមននៅហរិបុញ្ជ័យទៀតតែមិនបានជោគជ័យ ។ ប្រវត្តិវិទូបានចាត់ទុកថាស្តេចអង្គក្រោយនេះ គឺត្រូវនឹងព្រះបាទសូរ្យវរ្ម័ន ព្រោះនៅតំបន់ល្វោ(លពបុរី) គេបានរកឃើញសិលាចារឹករបស់ខ្មែរជាច្រើន ហើយទាក់ទងនឹងសូរ្យវរ្ម័នថែមទៀត ។ ចំពោះការវាតទីកដីខ្មែរក្នុងសម័យនោះ បើយើងពឹងផ្អែកលើកាលប្បវត្តិរបស់អ្នកស្រុកអាយ នោះយើងឃើញថាអំណាចគ្រប់គ្រងរបស់ខ្មែរបានគ្របដណ្តប់ទៅលើវាលទំនាបទន្លេមេណាមទាំងមូល និងវាលទំនាបទន្លេមេគង្គរហូតដល់ **វៀងចន្ទ** ឬក៏ហួសពីនេះទៅទៀត ប៉ុន្តែបើយើងពឹងផ្អែកទៅលើដំណែលបុរាណវត្ថុវិញ អំណាចនេះទៅមិនហួសពី **ឃ្មុំព្រះបាទ** នៅលើទន្លេមេគង្គនិងមិនហួសពី **សុខោទ័យ សុវណ្ណលោក** នៅលើទន្លេមេណាមទេ ។

ព្រះបាទសូរ្យវរ្ម័នទី១សោយទិវង្គតនៅគ.ស.១០៥០ ។ បុត្ររបស់ព្រះអង្គទាំងពីរបានឡើងសោយរាជ្យស្នងជាបន្តបន្ទាប់គ្នា ។

## ២. ព្រះបាទឧទយាទិត្យវរ្ម័នទី ២និងក្រុងអង្គរទី ២

ព្រះអង្គជាបុត្រច្បងនៃព្រះបាទសូរ្យវរ្ម័នទី១ ។ លុះបាទទទួលរាជសម្បត្តិហើយព្រះអង្គ ទ្រង់លើកព្រាហ្មណ៍បុរោហិតនៃទេវរាជនាម **សង្កាសិវជយេន្ទ្របណ្ឌិត** ដែលព្រះបិតាព្រះអង្គបានរៀបរាជាភិសេកជាមួយប្អូនថ្លៃស្រីរបស់ព្រះអង្គម្នាក់អោយឡើងឋានៈជា **ធូលីជេងព្រះកម្រតេងអញស្រីជយេន្ទ្រវរ្ម័ន** ។

គឺដោយអនុវត្តតាមគំនិតរបស់ព្រះគ្រូនេះហើយដែលព្រះបាទ **ឧទយាទិត្យវរ្ម័ន** ទ្រង់បានសាងប្រាសាទភ្នំថ្មីមួយទៀត គឺប្រាសាទ **បាពួន** ដែលជាផ្ចិតនៃក្រុង **អង្គរទី២** ។ ក្រុងថ្មីនេះមានកំពែងដីព័ទ្ធជុំវិញ ហើយស្ថិតនៅប្រហាក់ប្រហែលនឹងកន្លែងនៃក្រុងអង្គរទី ៣ របស់ព្រះបាទជយវរ្ម័នទី ៧ ។ ព្រម

ពេលជាមួយគ្នា ព្រះអង្គទ្រង់បានជីកបារាយមួយធំជាងបារាយដែលមានមកពីមុនៗគឺ **បារាយខាងលិច**ឬ **បារាយទឹកថ្លា** ដែលមានប្រវែង៨គ.ម. និងទទឹង២,២គ.ម. ហើយដាក់ទឹកបានប្រហែល៤០លាន ម៉ែត្រគ្រីគុណ(35) ។ នៅចំកណ្តាលបារាយនោះព្រះអង្គបានសាងប្រាសាទមួយ(**មេបុណ្យខាងលិច**)ដែលមានតំកល់បដិមាលង្ហិនមួយនៃព្រះវិស្ណុដែលកំពង់ផ្ទំ ។

ក្នុងវិស័យនយោបាយក្នុងប្រទេស សិលាចារឹកព្រះងោកបានអោយដឹងថាមានការបះបោរបីលើក ហើយសុទ្ធតែបានបង្រ្កាបអោយរាបទាបទៅវិញដោយមេទ័ពឈ្មោះ **សង្គ្រាម** ។ ការបះបោរទី១កើតឡើងនៅគ.ស.១០៥១នៅភាគខាងត្បូងហើយមានមេដឹកនាំឈ្មោះ **អរវិន្ទហ្រ្ទាន**តែត្រូវទទួលបរាជ័យ ហើយភៀសទៅចាម្ប៉ា ។ ការបះបោរលើកទី២កើតឡើងនៅគ.ស.១០៦៥នៅតំបន់ពាយ័ព្យ ហើយមានមេដឹកនាំឈ្មោះ **កមង** : ក្នុងលើកនេះគេឃើញពួកបះបោរវាយកំទេចសិវលិង្គនិងទេវបដិមានៅគ្រប់ទិសទី(19) ។ ក្រោយបន្តិច ការបះបោរលើកទី៣បានផ្ទុះឡើងនៅភាគខាងកើត ដឹកនាំដោយបងប្អូនពីរនាក់គឺ **ស្លូត**និង**សិទ្ធិការ** ដែលធ្វើសហប្រតិបត្តិការជាមួយមេម្នាក់ទៀតឈ្មោះ **សសាន្តិភូវន** ។

ព្រះបាទឧទយាទិត្យវរ្ម័នទី២ សោយទីវង្គតនៅគ.ស.១០៦៦ ។ គេមិនបានស្គាល់មរណនាមរបស់ព្រះអង្គទេ ។ ព្រះអនុជពៅនាម **ហរិវរ្ម័នទី៣** ឡើងសោយរាជ្យស្នងព្រះអង្គ ។

## ៣. ព្រះបាទហរិវរ្ម័នទី ៣

ក្រោយពីបានទទួលរាជសម្បត្តិហើយព្រះអង្គទ្រង់បានយកព្រះហឫទ័យទុកដាក់នឹងការកសាងជាតិឡើងវិញ ។ ប៉ុន្តែមិនដឹងជាអកុសលអ្វីព្រះអង្គត្រូវចូលធ្វើសង្គ្រាមពីរលើក មួយលើកច្បាំងនឹងចាម មួយលើកទៀតច្បាំងនឹងយួនដៃវៀត ។

នៅគ.ស.១០៧៤ព្រះអង្គម្ចាស់ **ថាង** អនុជស្តេចចាមបានលើកទ័ពចូលវាយយកក្រុងសម្ភុបុរ ដោយបំផ្លាញចោលនូវទេវាល័យទាំងអស់ ហើយកៀរខ្មែរយកជាឈ្លើយទៅជាមួយអស់ជាច្រើន ។ ទ័ពខ្មែរដែលដឹកនាំដោយក្សត្រ **ស្រីនន្ទវម៌ទេវ** ត្រូវទទួលបរាជ័យនៅ **សោមេស្វរ** (គេមិនស្គាល់កន្លែងច្បាស់) ប៉ុន្តែសន្តិភាពបានកើតឡើងវិញនៅគ.ស.១០៨០ ។

នៅ គ.ស.១០៧៦ ទ័ពខ្មែរត្រូវចិនប្រទាញអោយទៅជួយវាយយួនដៃវៀត ។ យ៉ាងណាមិញ នៅឆ្នាំនោះទ័ពចិននៃរាជវង្សសុង ក្រោមបញ្ជាការរបស់មេទ័ពឈ្មោះ **ក្វាច់គ្វី** បានលើកពីឡាងសឺង (Lang Son)សំដៅចុះមកហាណូយ ឯទ័ពខ្មែរ និងចាមចូលវាយលុកតំបន់ងេអាន(Nghe An) ។ គ្រានោះស្តេចយួនបញ្ជាអោយ **លីធឿង កៀត** (LyThuong Kiet)លើកទ័ពទៅតទល់នឹងចិន តែមិនចាញ់មិនឈ្នះ ។ ស្តេចយួនក៏បញ្ជូនទូតអោយទៅចរចាជាមួយរាជវង្សសុង ។ ដោយឃើញទ័ពខ្លួនត្រូវស្លាប់

អស់ជាងពាក់កណ្តាល (ជាង៤ម៉ឺននាក់)ចិនក៏ព្រមដកទ័ពថយ ។ ទ័ពខ្មែរ និងទ័ពចាមក៏ដកថយជាមួយដែរ(31) ។

ព្រះបាទហស៌វរ្ម័នទី៣សោយទីវង្គតនៅឆ្នាំ១០៨០ហើយទទួលមរណនាមថា **សទាសិវបទ** ។

## ឃ. រាជវង្សមហីធរបុរ

### ១. ព្រះបាទជ័យវរ្ម័នទី ៦

ស្តេចដែលសោយរាជ្យស្នងព្រះបាទហស៌វរ្ម័នទី៣នៅអង្គរ គឺព្រះបាទ **នច្ចតីន្ទ្រវរ្ម័ន** (១០៨០-១១១៣) ។ ប៉ុន្តែសិលាចារឹកបានអោយដឹងថា ក្នុងពេលជាមួយគ្នានោះមានស្តេចមួយអង្គទៀតសោយរាជ្យនៅក្រុង **មហីធរបុរ** ដែលគេមិនស្គាល់ទីកន្លែងប្រាកដនៅឡើយ តែប្រហែលខាងជើងឆៀងខាងលិច ត្រង់វាលទំនាបខាងលើនៃទន្លេមូល ។ ស្តេចទី២នេះគឺព្រះបាទជយវរ្ម័នទី៦ ។ ព្រះជីវប្រវត្តិតាមដែលគេដឹងសិលាចារឹកភ្នំរុង ឃើញថាគ្មានជាប់ញាតិជាមួយនឹងរាជវង្សមុនៗទេ គេគ្រាន់តែដឹងថា ព្រះអង្គជាបុត្រស្តេច **ហិរណ្យវរ្ម័ន** និងព្រះនាង **ហិរណ្យលក្ស្មី** ។ តាមសម្មតិកម្មរបស់ប្រវត្តិវិទូជយវរ្ម័នទី៦ ទំនងជាស្តេចក្រាញឈរត្រួតខេត្ត លុះឃើញអំណាចកណ្តាលចុះទន់ខ្សោយដោយមានការបះបោរ និងសង្គ្រាមជាញឹកញាប់ក្នុងរាជ្យមុនៗក៏តាំងប្រកាសខ្លួនជាមហាក្សត្រឡើង តែពុំបានមកសោយរាជ្យនៅអង្គរទេ ។ ពិធីអភិសេកព្រះបាទជយវរ្ម័នទី៦ត្រូវប្រារព្ធធ្វើឡើងដោយព្រាហ្មណ៍ **ទិវាករបណ្ឌិត** ដែលធ្លាប់បំពេញមុខងារជារាជបុរោហិតរបស់ព្រះបាទហស៌វរ្ម័នទី៣ ហើយប្រហែលដោយបានប្រាថ្នាលាភសក្ការៈ ក៏បានចាកចោលអង្គរទៅបំរើរាជវង្សថ្មីវិញ ។

ព្រះបាទជយវរ្ម័នទី៦ទ្រង់បានបន្តការកសាងនៅភ្នំសណ្តក នៅភ្នំព្រះវិហារនៅវត្តភូ និងនៅភិម៉ៃ (ខាងពុទ្ធសាសនា) ។ ពេលសោយទីវង្គតព្រះអង្គបានទទួលមរណនាមថា **បរមកៃវល្យបទ** ។

### ២. ព្រះបាទធរណីន្ទ្រវរ្ម័នទី១

ដោយពុំមានបុត្រសោយរាជ្យស្នង រាជសម្បត្តិត្រូវបានទៅព្រះបាទធរណីន្ទ្រវរ្ម័នទី១ ដែលត្រូវជាព្រះរៀមច្បងនៃព្រះបាទជយវរ្ម័ទី៦ នៅគ.ស.១១០៧ ។ បើតាមសិលាចារឹកបានចាត់ថា ព្រះអង្គពុំចង់ទទួលយករាជសម្បត្តិទេ ក៏ប៉ុន្តែដោយព្រះអនុជពៅជារាជទាយាទសោយទីវង្គតទៅហើយដោយមានពាក្យអង្វរករពីសំណាក់ជនផ្សេងៗផង ព្រះអង្គក៏ព្រមទទួលកាន់កាប់អំណាចហើយដោយយកព្រះហឫទ័យទុកដាក់ថែមទៀត ។ គឺរាជបុរោហិតនាមទិវាករបណ្ឌិតដដែល បានធ្វើពិធីអភិសេកព្រះអង្គទៀត ។

ព្រះបាទធរណីន្ទ្រវរ្ម័នទី១ ទ្រង់បានបន្តការស្ថាបនាផ្សេងៗ ដែលបានធ្វើខ្លះហើយក្នុងរាជ្យមុន ហើយបានរៀបអភិសេកជាមួយព្រះនាង **ទិជយេន្ទ្រលក្ស្មី** ដែលត្រូវជាអតីតអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៦ផងនិងរបស់ព្រះអនុជពៅផង ។

នៅឆ្នាំ១១១៣ព្រះអង្គត្រូវចៅមីងព្រះអង្គ(អនាគតសូរ្យវរ្ម័នទី២)ធ្វើគត់ដណ្តើមរាជ្យ ។ ព្រះអង្គមានមរណនាមថា **ចរមនិស្កលបទ** ។

## ៣. ព្រះបាទសូរ្យវរ្ម័នទី ២

សិលាចារឹកវត្តភូថា ព្រះបាទសូរ្យវរ្ម័នទី ២ទ្រង់បានឡើងសោយរាជ្យដោយបង្រួមអាណាចក្រពីរ ។ បើតាមន័យនេះអាណាចក្រទី១គឺជារបស់ធរណីន្ទ្រវរ្ម័នទី១ ដែលគេមិនស្គាល់រាជធានីពិតប្រាកដ ឯអាណាចក្រទី២គឺជារបស់នប្ធបតីន្ទ្រវរ្ម័នដែលបានសោយរាជ្យនៅអង្គរតាំងតែពី១០៨០ម្ល៉េះ ។ គឺព្រាហ្មណ៍ទិវាករវដដែល បានរៀបចំពិធីអភិសេកព្រះបាទសូរ្យវរ្ម័ទី២ នៅឆ្នាំ១១១៣ ។

លុះបានសោយរាជ្យហើយ ព្រះបាទសូរ្យវរ្ម័នី២ទ្រង់ព្យាយាមភ្ជាប់ចំណងមិត្តភាពជាមួយចិនឡើងវិញ ។ គណបេសកកម្មទូតពីរ ត្រូវបញ្ជូនទៅប្រទេសចិននៅឆ្នាំ១១១៦ និង១១២០ ។ ក្នុងវិស័យសឹកសង្គ្រាម ព្រះបាទសូរ្យវរ្ម័នទី២ទ្រង់បានធ្វើចម្បាំងច្រើនលើកច្រើនសាណាស់ ។ នៅផ្នែកខាងកើត ព្រះអង្គច្បាំងជាមួយនឹងយួនដៃវៀត រួចទៅជាមួយនឹងចាម្ប៉ាទៀត ។ បុព្វហេតុនៃចម្បាំងគឺបណ្តាលមកពីយួនដៃវៀតចេះតែអនុញ្ញាតអោយពួកក្បត់ខ្មែរនិងចាម ចូលជ្រកកោនក្នុងប្រទេសរបស់ខ្លួន (គ.ស. ១១២៣-១១២៤) ។ នៅគ.ស.១១២៨ព្រះអង្គលើកទ័ព៣២០០០០នាក់ចូលលុកប្រទេសដៃវៀត ប៉ុន្តែត្រូវមេទ័ព **លីកុងប៊ិញ** (Li Công -binh) រុញច្រានអោយថយចេញពីតំបន់ងេអាន ។ បន្ទាប់មកព្រះអង្គបានលើកទ័ពជើងទឹកដែលមានសំពៅ៧០០ចូលវាយលុកតំបន់ឆ្នេរសមុទ្រថាញ់វ៉ា (Thanh hoa) ទៀត ហើយចំណេរតមកចេះតែលើកទ័ពទៅរាតត្បាតប្រទេសនេះដោយប្រទាញប្រទេសចាម្ប៉ាអោយចូលដៃជាមួយផង ។ នៅគ.ស.១១៣១ទ័ពចំរុះខ្មែរ-ចាម បានវាយលុកតំបន់ងេអាន តែត្រូវរុញច្រាញអោយថយមកវិញទៀត ។ នៅគ.ស.១១៣៨ព្រះបាទសូរ្យវរ្ម័នទី២លើកទ័ពទៅវាយដៃវៀតម្តងទៀតតែស្តេចចាម **ជ័យឥន្ទ្រវរ្ម័នទី៣** មិនព្រមចូលរួមជាមួយខ្មែរទៀត ព្រះអង្គក៏លើកទ័ពចូលវាយចាម្ប៉ាម្តងវិញ ហើយកាន់កាប់បានរាជធានីវិជ័យ ពីឆ្នាំ១១៤៥ដល់១១៤៩ ។ ស្តេចចាមមួយអង្គទៀតនាម **ជ័យហរិវរ្ម័នទី១** ក្រោយពីបានឡើងសោយរាជ្យនៅ **ធាណ្ឌុរង្គ** ត្រូវចេញប្រយុទ្ធជាមួយនឹងទ័ពចំរុះខ្មែរ-ចាម ក្រោមបញ្ជាការរបស់សេនាបតី **សង្ករ** ហើយបានទទួលជោគជ័យនៅ **រាជបុរ** នៅគ.ស.១១៤៨ និងក្រោយមកទៀតនៅ **វីរបុរ** និងនៅទីបំផុតនៅ **មហិស** ដោយធ្វើគត់បានព្រះអង្គម្ចាស់ **ហរិទេវ** (ប្អូនថ្លៃសូរ្យវរ្ម័នទី២សោយរាជ្យនៅវិជ័យ) ហើយឡើងសោយរាជ្យនៅវិជ័យនៅគ.ស.១១៤៩ ។

ក្រោយពីបានថយចេញពីចាម្ប៉ាហើយ ព្រះបាទសូរ្យវរ្ម័នទី២បានលើកទ័ពទៅវាយយួនដៃវៀត លើកចុងក្រោយបង្អស់នៅគ.ស.១១៥០ ។ ប៉ុន្តែដោយទ័ពលើកទៅចំរដូវភ្លៀងខ្លាំង (កញ្ញា-តុលា) ទាហានត្រូវជម្ងឺរាតត្បាតអស់ថាមពលប្រយុទ្ធ ក៏ដកថយមកវិញដោយគ្មានបានច្បាំង ។

នៅផ្នែកខាងលិច ព្រះបាទសូរ្យវរ្ម័នទី២ ទ្រង់បានធ្វើចម្បាំងជាមួយពួកមន ។ ពត៌មានទាំងនេះគឺបានមកពីកាលប្បវត្តិនៃក្សត្របុរីថៃនៅវាលទំនាបខាងលើនៃទន្លេមេណាម ។ ឯកសារទាំងនោះបាននិយាយរៀបរាប់ពីចម្បាំងរវាងពួក **កម្ពោជ** (ខ្មែរ)នៅល្វោនិងពួក **រាមញ្ញ** (មន)នៅហរិបុញ្ជ័យ ។ បុព្វហេតុគឺបណ្តាលមកពីស្តេចមនឈ្មោះ **អាទិត្យរាជ**ដែលបានឡើងសោយរាជ្យប្រមាណនៅឆ្នាំ១១៥០ ។ ស្តេចនេះទំនងជាបានលើកទ័ព មកវាយខ្មែរនៅល្វោមុនតែត្រូវទ័ពខ្មែរដេញតាមរហូតដល់ក្រុងហរិបុញ្ជ័យ ។ ក្រោយមកខ្មែរបានលើកទ័ពទៅពីរលើកទៀតៈលើកទី១ ខ្មែរបានធ្វើកិច្ចព្រមព្រៀងជាមួយស្តេចអាទិត្យរាជដែលបានអនុញ្ញាតអោយជនជាតិខ្មែរចូលរស់នៅត្រង់ភូមិមួយហៅថា **កម្ពោជ-គ្រាម**នៅត្រង់អគ្នេយ៍ហរិបុញ្ជ័យ តែដោយស្តេចខ្មែរទ្រង់មិនយល់ព្រមតាមកិច្ចព្រមព្រៀងនោះ ទ័ពខ្មែរក៏លើកទៅជាលើកទី២តែលើកនេះបែរជាទទួលបរាជ័យទាំងស្រុង ។

បើតាមឯកសារទាំងប៉ុន្មានខាងលើនេះឃើញថា ចម្បាំងជាមួយយួនចាមមនក្តីសុទ្ធតែមិនសូវមានជោគជ័យប៉ុន្មានសោះ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ទឹកដីខ្មែរនៅសម័យនោះបានរីកធំទូលាយណាស់ សឹងមានឯកសារចិនបញ្ជាក់ថាខាងជើងទល់នឹងចាម្ប៉ាខាងកើតទល់នឹងសមុទ្រ ខាងលិចទល់នឹងបូកាន ខាងត្បូងទល់នឹងកៀឡូហ៊ី (Grahi នៅលើជ្រោយមលយូ) ។

នៅគ.ស.១១២៨ព្រះចៅក្រុងចិនបានថ្វាយឋានន្តរសក្តិយ៉ាងខ្ពង់ខ្ពស់ចំពោះស្តេចខ្មែរថា **គិនពីចពិនចេន** ប្រហែលត្រូវនឹងពាក្យខ្មែរថា **កម្រតេង** ។ ទំនាស់ខ្លះក្នុងផ្នែកពាណិជ្ជកម្មត្រូវបានសម្របសម្រួល នៅចន្លោះឆ្នាំ ១១៣១និង១១៤៧ ។

ក្នុងវិស័យសំនង់ព្រះបាទសូរ្យវរ្ម័នទី២ទ្រង់បានបន្តការស្ថាបនាប្រាសាទភ្នំជីសូរ ប្រាសាទភ្នំសណ្តកប្រាសាទវត្តភូ ប្រាសាទព្រះវិហារ ។ ចំណែកឯសំនង់ថ្មីមានជាអាទិប្រាសាទ **ព្រះពិធូរ** ប្រាសាទ **ចៅសាយទេវតា** និង**ធម្មានន្ទ បន្ទាយសំរែ** និង**អង្គរវត្ត**ដែលជាស្នាដៃឯកនៃសិល្បៈខ្មែរដើម្បីតំកល់ព្រះវិស្ណុបដិមា ដែលមានមរណនាមថា **បរមវិស្ណុលោក** ។ ត្រង់នេះបង្ហាញអោយឃើញថានេះជាលើកដំបូងហើយដែលសាសនាព្រាហ្មណ៍គណៈវិស្ណុត្រូវបានព្រះរាជាលើកតំកើង អោយមានឋានៈជាសាសនាសំរាប់រដ្ឋ ។ អង្គរវត្តនៅតែជាប្រាសាទភ្នំដដែល តែបដិមាតំណាងព្រះរាជាលែងជាសិវលិង្គទៀតហើយ តែជាព្រះវិស្ណុបដិមាវិញ ។



*ការកសាងប្រាសាទអង្គរវត្ត (ស.វ.ទី ១២ )*

ព្រះបាទសូរ្យវរ្ម័នទី២ សោយទីវង្គតនៅឆ្នាំណាគេមិនដឹងប្រាកដទេ ។

## ៤. ព្រះបាទធរណីន្ទ្រវរ្ម័នទី២ និងយសោវរ្ម័នទី២

ព្រះបាទធរណីវរ្ម័នទី ២ ជាបងប្អូនជីដូនមួយបានទទួលរាជសម្បត្តិពីព្រះបាទសូរ្យវរ្ម័នទី ២ ។ ដោយព្រះអង្គជាពុទ្ធសាសនិកជនព្រះអង្គក៏បានបោះបង់ចោលនូវប្រពៃណីខាងសាសនាព្រាហ្មណ៍ដែលមានយូរណាស់មកហើយ ។ ព្រះអង្គមានអគ្គមហេសីនាម **ចូឌាមណិ** ជាបុត្រីព្រះបាទហស៊ីវរ្ម័នទី ៣ ។ នៅប្រមាណឆ្នាំ១១២៥ព្រះអង្គមានបុត្រឈ្មោះ **ជយវធិន** ដែលជាអនាគតព្រះបាទជយវរ្ម័នទី៧ ។

ស្តេចដែលសោយរាជ្យស្នងព្រះអង្គគឺ ព្រះបាទ **យសោវរ្ម័នទី២** ដែលគេមិនស្គាល់ព្រះជីវប្រវត្តិ ។ សិលាចារឹកនិងរូបចម្លាក់ប្រាសាទបន្ទាយឆ្មារ បានអោយដឹងថា យសោវរ្ម័នទី២ត្រូវ **រាហូ** វាយលុកតែបានយុវក្សត្រមួយអង្គជួយសង្គ្រោះ ទំនងជាបុត្រណាមួយរបស់អនាគតជយវរ្ម័នទី៧ ។ នៅឆ្នាំ១១៦៥ មានមន្ត្រីជាន់ខ្ពស់ម្នាក់ បានដណ្តើមរាជ្យដោយយកនាមថា **ត្រិភូវនាទិត្យវរ្ម័ន** ។ ព្រះអង្គម្ចាស់ជយវធ៌ន ក៏ប្រញាប់ប្រញាល់យាងត្រឡប់មកពីចាម្ប៉ាវិញ ដើម្បីជួយសង្គ្រោះព្រះបាទយសោវរ្ម័នទី២តែមិនទាន់ ។ នៅឆ្នាំ១១៧៧ស្តេចចាមនាម **ជយឥន្ទ្រវរ្ម័នទី៤** ដែលជាស្តេចជ្រែករាជ្យដែរ បាន លើកទ័ពជើងទឹកចូលវាយខ្មែរដោយមានចិនលិចសំពៅម្នាក់ជួយនាំផ្លូវ ។ ទ័ពនោះបានចូលតាមទន្លេមេគង្គ ហើយ

ឡើងរហូតដល់បឹងទន្លេសាប ។ ក្រុងអង្គរត្រូវធ្លាក់ក្នុងកណ្តាប់ដៃចាម ហើយស្តេចព្រៃនគរជ្បត្រិភូវនាទិត្យវរ្ម័នក៏ត្រូវធ្វើគត់ក្នុងសមភូមិ ។

## ៥. ព្រះបាទជយវរ្ម័នទី ៧

គេដឹងថាព្រះអង្គម្ចាស់ ជ័យវធ៌ន ត្រូវជាបងប្អូនជីទួតមួយ និងសូរ្យវរ្ម័នទី២ ។ នៅពេលដែលមិនទាន់បានសោយរាជ្យនៅឡើយព្រះអង្គបានរៀបរាជាភិសេកជាមួយនឹងព្រះនាង **ជ័យរាជទេវី** ។ ព្រះអង្គត្រូវបញ្ជាអោយលើកទ័ពទៅវាយចាមនៅតំបន់វិជ័យ ។ ពេលដែលព្រះបិតាសោយទីវង្គតទៅព្រះអង្គគង់នៅប្រទេសចាម្ប៉ានៅឡើយ ។ សិលាចារឹកភិមានាកាសបានអោយដឹងថា នៅពេលដែលយសោវរ្ម័នទី២ ត្រូវរងគ្រោះដោយមន្ត្រីម្នាក់ ព្រះអង្គក៏ប្រញាប់ប្រញាល់យាងមកវិញ រួចមកក៏មានអំពើឈ្លានពានរបស់ចាមវាយលុកយកបានរាជធានីអង្គរ ។

ព្រះបាទជ័យវរ្ម័នទី៧ មានគុណបំណាច់មួយយ៉ាងធំចំពោះប្រទេសជាតិ ដោយបានធ្វើការរំដោះទឹកដីអោយរួចផុតពីការ ត្រួតត្រារបស់បរទេស ។ ដើម្បីសំរេចគោលដៅ ព្រះអង្គត្រូវប្រយុទ្ធយ៉ាងស្វិតស្វាញប្រឆាំងនឹងពួកឈ្លានពាន ហើយទីបំផុតក៏បានទទួលជោគជ័យជាស្ថាពរក្នុងចម្បាំងជើងទឹកដែលមានរូបចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ននិងបន្ទាយឆ្មារជាសក្ខីភាព ។

នៅគ. ស. ១១៨១គឺនៅពេលដែលព្រះអង្គមានព្រះជន្មាយុ៥៦វស្សាទៅហើយ ទើបព្រះអង្គបានទទួលរាជាភិសេកឡើងសោយរាជ្យនៅយសោធរបុរ ។ កិច្ចការដំបូងដែលត្រូវបំពេញជាបន្ទាន់ គឺការរៀបចំរាជធានីឡើងវិញដោយស្ថាបនាកំពែងថ្មបាយក្រៀមនិងគូទឹកព័ទ្ធជុំវិញ មានប្រវែង ៣គ.ម. ក្នុងមួយជ្រុងៗ : នេះជា **អង្គរធំ៣** ឬ **អង្គរធំ** សព្វថ្ងៃនេះឯង ។

នៅខាងក្នុងប្រទេស ការបះបោរមួយក៏បានផ្ទុះឡើងនៅតំបន់ **មល្យាង**(ខាងត្បូងខេត្តបាត់ដំបង) ។ ព្រះបាទជ័យវរ្ម័នទី៧ ក៏បញ្ជាស្តេចចាមមួយអង្គនាម **វិទ្យានន្ទន៍** អោយលើកទ័ពទៅបង្ក្រាបបានរាបទាបឡើងវិញ ។ គួរបញ្ជាក់ថាក្សត្រចាមនេះបានមករស់នៅ នៅអង្គរតាំងតែពីក្មេងម្ល៉េះ ។ ដោយឃើញថាបានទទួលជោគជ័យដូចប្រាថ្នាហើយ ព្រះអង្គទ្រង់ប្រទានអោយនូវបុណ្យសក្តិ(យុវរាជ)និងទ្រព្យសម្បត្តិគ្រប់បែបយ៉ាង ។

ចំពោះការវាយលុកយ៉ាងសម្បើមរបស់ជនជាតិចាមនៅគ. ស. ១១៧៧ព្រះបាទជ័យវរ្ម័នទី៧បានសច្ចាថានឹងធ្វើការសងសឹកអោយទាល់តែបាន ។ នៅគ. ស. ១១៩០ព្រះអង្គទ្រង់ធ្វើអោយប្រទេសយួនដៃវៀតនៅអព្យាក្រិត្យ ដើម្បីអោយងាយស្រួលក្នុងការវាយចាម ។ ក្នុងឆ្នាំដដែល ឱកាសល្អក៏ហុចអោយដោយស្តេចចាមជ័យឥន្ទ្រវរ្ម័នទី៤លើកទ័ពមកវាយខ្មែរម្តងទៀត ។ ព្រះបាទជ័យវរ្ម័នទី ៧ក៏បញ្ជាវិទ្យា

ននន្ទន៍អោយលើកទ័ពទៅទប់ទល់ ។ វិទ្យានន្ទន៍វាយយកបានក្រុងវិជ័យ ហើយចាប់ស្តេចចាមជ័យឥន្ទ្រវរ្ម័នទី៤ ជាឈ្លើយមកថ្វាយជ័យវរ្ម័នទី៧ ។ ព្រះអង្គបានលើកព្រះអនុជថ្លៃនៃព្រះបាទជ័យវរ្ម័នទី៧ ឈ្មោះ **អិន** (អនុជ ព្រះនាងជ័យរាជទេវី) អោយឡើងសោយរាជ្យនៅវិជ័យដោយមាននាមថា **សូរ្យជ័យវរមិទេវ** រួចព្រះអង្គលើកទ័ពបង្ហួសទៅវាយយកក្រុង **បាណ្ឌុរង្គ** ហើយឡើងសោយរាជ្យនៅទីនោះដោយមាននាមថា **សូរ្យវរមិទេវ** ។ តែមិនយូរប៉ុន្មានពួកចាមនៅវិជ័យបះឡើងហើយ បណ្តេញអោយព្រះអង្គម្ចាស់អិនរត់ចូលទៅស្រុកខ្មែរវិញហើយលើកស្តេចចាមនាម **រសុបតិ** អោយឡើងសោយរាជ្យជាជំនួសវិញ ។ ឆ្លៀតឱកាសនេះ វិទ្យានន្ទន៍ បានបង្រួបបង្រួមប្រទេសចាមអោយមានឯកភាពឡើងវិញក្រោយពីបានធ្វើគតជ័យឥន្ទ្រវរ្ម័នទី៥(រសុបតិ) ហើយឡើងសោយរាជ្យលើប្រទេសចាម្ប៉ាទាំងមូលពីឆ្នាំ ១១៩២ដល់១២០៣ ។ នៅឆ្នាំ១១៩៣ និង១១៩៤ ព្រះបាទជ័យវរ្ម័នទី៧ទ្រង់បានសាកល្បងណែនាំអោយវិទ្យានន្ទន៍ទទួលស្គាល់អំណាចព្រះអង្គវិញតែឥតប្រយោជន៍ រហូតដល់ឆ្នាំ១២០៣ ព្រះអង្គបានបញ្ជាស្តេចចាមមួយអង្គទៀតនាម **អុងធនបតិគ្រាម** ដែលត្រូវជាឪពុកមាវិទ្យានន្ទន៍អោយលើកទ័ពទៅវាយកំចាត់ក្មួយព្រះអង្គទាល់តែបាន ។ វិទ្យានន្ទន៍ក៏រត់ទៅសុំជ្រកកោននឹងប្រទេសដៃវៀតតែស្តេចយួនមិនព្រមក៏រត់ទៅទៀតទាល់តែបាត់ដំណឹងតាំងពីពេលនោះមក ។

ចាប់ពីឆ្នាំ១២០៣ដល់១២២០ប្រទេសចាម្ប៉ាក៏ក្លាយទៅជាអាណាខេត្តមួយរបស់ខ្មែរ ស្ថិតក្រោមការគ្រប់គ្រងរបស់អុងធនបតិគ្រាមតែម្តង ។ នៅគ.ស.១២០៧ព្រះបាទជ័យវរ្ម័នទី៧បានបញ្ជាក្សត្រចាមមួយអង្គទៀតនាម **អនុរាជ** អោយលើកទ័ពចំរុះខ្មែរ-ភូមា-សៀម ទៅវាយប្រទេសដៃវៀតទៀត តែគេមិនដឹងថាបានទទួលលទ្ធផលយ៉ាងណាទេ ។

នៅដើមស.វ.ទី១៣គឺក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ទឹកដីខ្មែរមានទំហំធំទូលាយជាងពេលណាៗទាំងអស់ ។ គេបានរកឃើញសិលាចារឹករបស់ព្រះអង្គមួយនៅសាយហ្វុង នៅទល់មុខនឹងវៀងចន្ទក្នុងប្រទេសឡាវសព្វថ្ងៃ ហើយមានចុះកាលកំណត់១១៨៦ ។

តាមកំណត់របស់លោកចាវជូក្វា (Tchao Jou- Koua) ឆ្នាំ១២២៥ប្រទេសខ្មែរជំនាន់នោះបានត្រួតត្រាប្រទេសមលយូមួយផ្នែកនិងរហូតដល់ប្រទេសភូមាថែមទៀត ។ សិលាចារឹកព្រះខាន់(១១៩១)ក៏បានផ្តល់ពត៌មានពីស្តេចដែលចំណុះស្តេចខ្មែរគឺមានស្តេចជ្វា ស្តេចយួន(យវន)និងស្តេចចាមទាំងពីរ (សូរ្យជយវម៌ទេវនិងសូរ្យម៌ទេវ) ។

ក្រោយពីព្រះនាងជយរាជទេវីសោយទីវង្គតទៅ ព្រះបាទជ័យវរ្ម័នទី៧បានរៀបរាជាភិសេកជាមួយព្រះនាង **ឥន្ទ្រទេវី** ដែលជាបងបង្កើតរបស់ព្រះនាងជយរាជទេវី ។




ផែនទីព្រំដែនសម័យជ័យវរ្ម័នទី៧

ក្សត្រអង្គនេះជាស្ត្រីសម្បូណ៌ដោយចំណេះវិជ្ជា : ព្រះនាងត្រូវបានតែងតាំងជាសាស្ត្រាចារ្យក្នុងវត្តព្រះពុទ្ធសាសនាមួយ ហើយបានកសាងសិលាចារឹកភិមានាកាស ដែលជាប្រភពពត៌មានយ៉ាងសំខាន់ទាក់ទងនិងព្រះជីវប្រវត្តិជ័យវរ្ម័នទី ៧ ។

គេមិនដឹងច្បាស់ថាព្រះបាទជ័យវរ្ម័នទី៧សោយទីវង្គតទៅនៅឆ្នាំណាទេ ។ ព្រះអង្គទំនងជាបានសោយរាជ្យរហូតដល់ឆ្នាំ១២១៨ ។ ព្រះអង្គមានមរណនាមថា **មហាបរមសៅគត** ។ ព្រះនាមនេះសអោយឃើញថា ព្រះអង្គជាពុទ្ធសាសនិកជនមួយរូបតែទោះបីយ៉ាងហ្នឹងក៏ដោយក៏ព្រះអង្គមានព្រាហ្មណ៍បុរោហិតម្នាក់ ឈ្មោះ **ហាឬសីកេស** ជាសក្ខីភាពប្រាប់ថាសាសនាព្រាហ្មណ៍នៅពេលនោះ នៅមានឥទ្ធិពលខ្លាំងគួរសមដែរ ថ្វីបើលទ្ធិទេវរាជត្រូវទទួលអន្លងមួយយ៉ាងធ្ងន់ពីសំណាក់ពួកចាមដែលចូលលុកលុយនៅឆ្នាំ១១៧៧ ។

ក្នុងវិស័យសំនង់ គេអាចចាត់ទុកថាព្រះបាទជ័យវរ្ម័នទី៧ជាអ្នកកសាងសមិទ្ធិច្រើនជាងគេបំផុត ។ ដូចយើងបានឃើញពីខាងដើមរួចមកហើយស្នាព្រះហស្តចម្បងរបស់ព្រះអង្គគឺក្រុង **អង្គរធំ៣** ដែលមានកំពែងនិងគូទឹកព័ទ្ធជុំវិញ មានគោបុរៈ៥ និងមានប្រាសាទ **បាយ័ន** នៅចំកណ្តាល ។ នៅជុំវិញក្រុងមានប្រាសាទ **បន្ទាយក្តី តាព្រហ្ម ព្រះខាន់ នាគព័ន្ធ តាសោម ក្រោលគោ** និងប្រាសាទជាច្រើនទៀតនៅតាមខេត្តដូចជា បន្ទាយឆ្មារ (បាត់ដំបង) **បន្តេនគរ** (កំពង់ចាម) **តាព្រហ្ម** (បាទី ) : ទាំងអស់សុទ្ធសឹងមានប្រាង្គមុខ៤បែរទៅរកទិសទាំង៤ ។ ក្រៅពីប្រាសាទនៅមានសាលាសំណាក់ (ឬធម៌សាលា) ចំនួន១២១និងមន្ទីរពេទ្យចំនួន១០២ ។

- ប្រាសាទបន្ទាយក្តីឬ **បវិតបាគត** ទំនងជាបានសាងមុនគេហើយមានស្រះស្រង់នៅពីខាងកើត។

- ប្រាសាទតាព្រហ្មឬ **រាជវិហារ** សាងឡើងនៅឆ្នាំ១១៨៦ ដើម្បីឧទ្ទិសចំពោះវិញ្ញាណក្ខន្ធនៃព្រះមាតានិងរាជគ្រូឈ្មោះ **ជយមង្គលាថ៌** ។ រូបតំណាងព្រះបិតាគឺ បដិមានាងប្រជ្ញាបារមិតា ។

- ប្រាសាទព្រះខាន់ ឬ **ជ័យស្រី** សាងឡើងក្នុងឆ្នាំ១១៩១ ដើម្បីឧទ្ទិសចំពោះព្រះបិតាដោយមានរូបតំណាងជាបដិមាពោធិសត្វលោកេស្វរឈ្មោះ **ជយវរមេស្វរ** ។

- ប្រាសាទនាគព័ន្ធឬ **រាជ្យស្រី** សាងនៅកណ្តាលស្រះរាង៤ជ្រុង ។ នៅទីនោះគេមានតំកល់ពោធិសត្វលោកេស្វរដែលមានរូបជាសេះឈ្មោះ **ពលាហះ** ដែលបានជួយស្រោចស្រង់ពួកអ្នករងគ្រោះដោយលិចសំពៅ ។ គេថាស្រះនេះជាតំណាងស្រះ **អនវតាប្ត** ស្ថិតនៅភ្នំហេមពាន្ត ហើយមានទឹកសក្តិសិទ្ធ ណាស់អាចជួយព្យាបាលជម្ងឺគ្រប់បែបយ៉ាង ។

- ប្រាសាទបន្ទាយឆ្មារ សាងឡើងឧទ្ទិសចំពោះរាជបុត្រព្រះនាម **ស្រីន្ទ្រកុមារ** ហើយ និងសញ្ជកទាំង៤នាក់ដែលបានរួមគ្នាប្រយុទ្ធជាពិសេសក្នុងការបះបោររបស់រាហូនិងក្នុងចម្បាំងនៅប្រទេសចាម្ប៉ា ។

- ប្រាសាទបាយ័ន បានកសាងឡើងនៅខាងចុងរជ្ជកាលរបស់ព្រះបាទជយវរ្ម័នទី៧ ។ ប្រាសាទនេះស្ថិតនៅចំផ្ចិតនៃក្រុងអង្គរធំដែលមានកំពែងព័ទ្ធជុំវិញ ។ ទោះបីគេដឹងថាប្រាសាទនេះត្រូវរុះរើហើយកែប្រែជាច្រើនលើកច្រើនសាហើយក៏ដោយ ក៏គេអាចសន្និដ្ឋានថាបាយ័នជាប្រាសាទភ្នំរបស់ព្រះបាទជ័យវរ្ម័នទី៧ ប៉ុន្តែនៅក្នុងប្រាង្គកណ្តាលគេមិនតំកល់សិវលិង្គទៀតទេបែរជាតំកល់បដិមាពុទ្ធរាជមួយអង្គយ៉ាងធំសម្បើម(កំពស់ជិត៤)ទៅវិញ ។ នេះហើយជាទេពកោសល្យរបស់ជយវរ្ម័នទី៧ ដែលទ្រង់ចេះសម្របសម្រួល អ្វីដែលជារបស់សាសនាមានពីមុន(ប្រាសាទភ្នំ)និងអ្វីដែលជាថ្មី(ពុទ្ធរាជ) ដើម្បីអោយបានពេញចិត្តទាំងពួកព្រាហ្មណ៍ទាំងពួករាស្ត្រ។ ជាលើកដំបូង គេឃើញលើជញ្ជាំងប្រាសាទនេះទាំងក្នុងថែវខាងក្នុងនិងខាងក្រៅនូវចម្លាក់ពិពណ៌នាពីជីវភាពរបស់ប្រជារាស្ត្រទូទៅដែលអ្នកស្រាវជ្រាវបានចាត់ទុកថាជាឯកសារមួយយ៉ាងសំខាន់សំរាប់ឆ្លុះមើលសង្គមខ្មែរក្នុងសម័យនោះ ។ គួរកត់សំគាល់ថាប្រាសាទបាយ័នមាន ប្រាង្គមុខ៤ទាំងអស់៥៤ហើយនៅគ្រប់ជាន់ថ្នាក់ ។ អ្នកស្រាវជ្រាវខ្លះមានយោបល់ថាប្រាសាទនេះជា រូបភាពនៃអាណាចក្រទាំងមូលដែលគេបង្រួញ : ប្រាង្គនិមួយៗជានិមិត្តរូបនៃខេត្តខណ្ឌមួយ ចំណែកឯមុខទាំង៤ គឺតំណាងព្រះភក្ត្រព្រះរាជាឬមហិទ្ធិរិទ្ធិរបស់ព្រះអង្គដែលផ្សព្វផ្សាយទៅគ្រប់ទិសទី ។

សិលាចារឹកព្រះខាន់បានអោយដឹងថា មានការកសាងលាសាសំណាក់១២១ នៅតាមបណ្តោយផ្លូវធំៗនៃអាណាចក្រមានចម្ងាយ១៥គម. ពីមួយទៅមួយទៀត :

- ពីអង្គរទៅចាម្ប៉ា : ៥៧ សាលា
- ពីអង្គរទៅភិម៉ៃ : ១៧ សាលា
- កន្លែងដទៃទៀត : ៤៤ សាលា
- ភ្នំជីសូរ : សាលា ១

សិលាចារឹកតាព្រហ្មបានអោយដឹងពីការកសាងមន្ទីរពេទ្យចំនួន១០២ នៅពាសពេញផ្ទៃប្រទេស ។ សព្វថ្ងៃគេបានរកឃើញកន្លែងនៃមន្ទីរទេព្យនោះចំនួន១៥កន្លែង ដោយសារផ្ទាំងសិលាចារឹកសំស្ក្រិតនិយាយពីការកសាងពីការរៀបចំ និងដំណើរប្រព្រឹត្តទៅនៃគ្រឹះស្ថានទាំងនោះ ។ គួរកត់សំគាល់ថាមនុស្សក្នុងវណ្ណៈទាំង៤ អាចចូលព្យាបាលជម្ងឺក្នុងមន្ទីរពេទ្យនោះបានដូចគ្នា។

## ៦. ព្រះបាទឥន្ទ្រវរ្ម័នទី ២

ព្រះបាទជ័យវរ្ម័នទី៧ មានបុត្រច្រើន តែគេមិនដឹងច្បាស់ថាបុត្រអង្គណាមួយបានសោយរាជ្យស្នងព្រះអង្គដោយមាននាមថា **ឥន្ទ្រវរ្ម័នទី២** ទេ ។ នៅឆ្នាំ១២១៦ និង១២១៨ ទ័ពចំរុះខ្មែរ-ចាម បានលើក

ទៅវាយយួនដៃវៀតម្តងទៀតនៅតំបន់ងេអាន ប៉ុន្តែត្រូវដកថយមកវិញទៀត ។ នៅឆ្នាំ១២២០ខ្មែរបានថយពីចាម្ប៉ាដោយខ្លួនឯង ហើយលើកស្តេចចាមឈ្មោះអង្សរាជអោយឡើងសោយរាជ្យនៅវិជ័យ ។ បុព្វហេតុនៃការដកថយនេះទំនងជា បណ្តាលមកពីការរើបំរាស់របស់ជនជាតិថៃនៅត្រង់វាលទំនាបនៃទន្លេមេណាម ។ យ៉ាងណាមិញវិវាទបានកើតឡើងរវាងចៅហ្វាយខេត្តខ្មែរនិងមេដឹកនាំថៃពីរនាក់ នៅសុខោទ័យ ។ ក្រោយពីក្រុងសុវណ្ណលោកត្រូវវាយយកបាន ចៅហ្វាយខេត្តខ្មែរត្រូវភៀសខ្លួនចេញពីសុខោទ័យ ។ ប្រមាណជានៅគ. ស. ១២២០ មេដឹកនាំថៃម្នាក់បានឡើងសោយរាជ្យដោយមាននាមថា **ឥន្ទ្រាទិត្យ** (39) ។

## ខ. ប្រតិកម្មសិវនិយមប្រឆាំងនិងពុទ្ធសាសនា

### ១. ព្រះបាទជ័យវរ្ម័នទី៨

ស្តេចដែលបានសោយរាជ្យជាបន្តពីព្រះបាទឥន្ទ្រវរ្ម័នទី២ គឺព្រះបាទ **ជ័យវរ្ម័នទី៨** តែតាមគេស្មានមើលទៅគឺមិនមែនក្រោយផ្ទាល់តែម្តងទេ ។

ព្រឹត្តិការណ៍សំខាន់ៗ ដែលគេបានកត់សំគាល់ឃើញក្នុងរជ្ជកាលរបស់ព្រះអង្គមានដូចតទៅ :

១. ក្នុងផ្នែកនយោបាយក្រៅប្រទេស ព្រះបាទជយវរ្ម័នទី៨ ត្រូវឈមមុខតទល់ជាមួយនឹងជនជាតិសៀម ដែលបានបន្តការបះបោរប្រឆាំងនឹងខ្មែរ នៅត្រង់វាលទំនាបកណ្តាលនៃទន្លេមេណាម ។

២. នៅខាងក្នុងប្រទេស ព្រះបាទជ័យវរ្ម័នទី៨ត្រូវឈមមុខតទល់នឹងជនជាតិម៉ុងហ្គោល ដែលបានធ្វើការឈ្លានពានមកលើអាស៊ីអគ្នេយ៍ទាំងមូលក្រោយពីបានវាយយកបានប្រទេសចិន (១២០៥-១២៧០) ។ ហើយបង្កើតរាជវង្សឡើងសោយរាជ្យនៅលើប្រទេសនេះ(១២៧៩-១៣៦៨) ។ ដូច្នេះនៅគ. ស. ១២៨៣ ក្រោយពីបានវាយយកបានភាគខាងជើងនិងភាគកណ្តាលនៃប្រទេសចាម្ប៉ាហើយឧត្តមសេនីយ៍ **សូហ្គាតូ** (Sogatou) មេបញ្ជាការនៃកងទ័ពម៉ុងហ្គោល បានបញ្ជូនមេទ័ពពីរនាក់គឺ មេរយនិងមេពាន់ អោយចូលមកលុកលុយប្រទេសកម្ពុជា ហើយត្រូវទ័ពខ្មែរចាប់បានជាឈ្លើយទាំងពីរនាក់ ។ ទោះបីយ៉ាងហ្នឹងក៏ដោយ ក៏ព្រះបាទជ័យវរ្ម័នទី៨ទ្រង់ឈ្វេងយល់ថាគួរតែលើកសួយសារអាករទៅថ្វាយព្រះចៅ **គូប៊ីឡៃខាន់** ( K'oubilai Khan) នៅឆ្នាំ១២៨៥ ។ ដូច្នេះឃើញថាទំនាក់ទំនងជាមួយប្រទេសចិនត្រូវអាក់ខានអស់តែមួយរយៈពេលដ៏ខ្លីតែបុណ្ណោះ ។

៣. ប្រតិកម្មយ៉ាងខ្លាំងក្លាពីសំណាក់អ្នកកាន់សាសនាព្រាហ្មណ៍ប្រឆាំងនឹងពុទ្ធសាសនា ។ ដោយហេតុហ្នឹងហើយបានជាគេឃើញមានការកោសលុបរូបចម្លាក់ព្រះពុទ្ធនៅលើជញ្ជាំងនិងលើសសរ និងការសាងជំនួសវិញដោយលិង្គព្រះឥសូរឬតាបសតាំងសីល ។

ពត៌មានដែលទាក់ទងទៅនឹងស្តេចដែលសោយរាជ្យតពីព្រះបាទជយវរ្ម័នទី៧ គឺមានមកពីសិលាចារឹកកសាងឡើងដោយពួកព្រាហ្មណ៍ដែលចង់ប្រស់ប្រពៃណីព្រាហ្មណ៍ក្នុងសតវត្សមុនៗអោយរស់រវើក ឡើងវិញ ក្រោយពីត្រូវបាត់ឈ្មោះបោះសំលេងក្នុងរជ្ជកាលរបស់ព្រះបាទធរណីន្ទ្រវរ្ម័នទី២ ព្រះបាទជ័យវរ្ម័នទី៧និងអគ្គមហេសីរបស់ព្រះអង្គ ។ ក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៨ពួកព្រាហ្មណ៍បានទទួលអនុគ្រោះសាជាថ្មីឡើងវិញ ។ មហេសីរបស់ព្រះអង្គមួយរូបគឺព្រះនាង **ចក្រវិតិ-រាជទេវី** ត្រូវជាកូនស្រីរបស់ព្រាហ្មណ៍បុរោហិត ហឫសីកេស ដែលបានមកពីប្រទេសភូមាក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧ ហើយដែលបានទទួលឋានន្តរនាមថា **ជយមហាប្រធាន** ។ ប្អូនថ្លៃស្រីរបស់ព្រាហ្មណ៍នេះបានរៀបការជាមួយព្រាហ្មណ៍ម្នាក់ទៀត ឈ្មោះ **ជយមនលាថិ** ។ នាងមានកូនម្នាក់ដែលមានឈ្មោះដូចគ្នានឹងព្រាហ្មណ៍ឪពុកដែរ ។ ព្រះបាទជ័យវរ្ម័នទី៨ ទ្រង់ផ្តល់កិត្តិយសយ៉ាងធំចំពោះជយមន្គលាថិជាកូននេះរហូតបានបញ្ជាអោយស្ថាបនាប្រាសាទមួយនៅឆ្នាំ១២៩៥ ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធនៃបុរសរូបនេះ ដែលបានទៅជាបងប្អូនជីដូនមួយរបស់អគ្គមហេសីព្រះអង្គ ។ ម្យ៉ាងទៀតសិលាចារឹកសំស្រ្កិតចុងក្រោយបង្អស់នៅប្រទេសខ្មែរ(សិលាចារឹកអង្គរវត្ត)បានផ្តល់ពត៌មានពីព្រាហ្មណ៍ម្នាក់ទៀតឈ្មោះ **វិទ្យេសវិន**ជាកូនចៅរបស់ព្រាហ្មណ៍ **សវិជ្ជមុនិ** មានដើមកំណើតនៅប្រទេសឥណ្ឌា ។

៤-ទោះបីមានប្រតិកម្មយ៉ាងខ្លាំងក្លាពីសំណាក់ពួកព្រាហ្មណ៍ ដូចមានរៀបរាប់រួចមកហើយក៏ដោយក៏គេឃើញថាពុទ្ធសាសនាថេរវាទបានផ្សព្វផ្សាយចូលមកដល់ប្រទេសខ្មែរហើយមានអ្នកកាន់ក៏កាន់តែច្រើនឡើងៗហើយដែរ ។ ឯការនាំចូលមកក្នុងប្រទេសខ្មែរនេះគឺជាស្នាព្រះហស្តរបស់ព្រះអង្គម្ចាស់ **តាមលិន្ទ** ជាបុត្ររបស់ព្រះបាទជ័យវរ្ម័នទី៧ ។ កាលប្បវត្តិភូមាបានដំណាលថាមានជនជាតិមនម្នាក់ឈ្មោះ **ឧត្តរជីវ** បានធ្វើដំណើរទៅកោះសេរីលង្កា នៅឆ្នាំ១១៨០ជាមួយអ្នកបួសមួយក្រុម ។ ក្នុងចំណោមនោះមានសាមណេរ មានឈ្មោះ **ឆបដ**បានស្នាក់នៅទីនោះអស់រយៈពេល១០ឆ្នាំ ហើយបានត្រឡប់មកវិញនៅឆ្នាំ១១៩០ជាមួយអ្នកបួស៤នាក់ដែលបានទទួលការបំបួសនៅវត្ត **មហាវិហារ** ក្នុងចំណោមនោះមានព្រះអង្គម្ចាស់តាមលិន្ទ ជាបុត្ររបស់ព្រះចៅប្រទេសកម្ពុជា ។

នៅចុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៨គឺនៅ១ ២៩៥គណៈបេសកកម្មចិនមួយត្រូវបានបញ្ជូនមកដើម្បីចរចាពីរឿងសួយសារអាករហើយបានមកដល់ប្រទេសខ្មែរនៅឆ្នាំ១២៩៦ ។ លោកជីវតាក្វាន់ដែលធ្វើដំណើរមកជាមួយដែរ ហើយដែលបានស្នាក់នៅនៅស្រុកខ្មែរអស់រយៈពេលជាងមួយឆ្នាំ បានធ្វើការកត់ត្រាពីទឹកដី ពីការរស់នៅនិងពីទំនៀមទំលាប់របស់ខ្មែរនៅចុងសតវត្សទី១៣ ។ ពត៌មានដ៏មានតម្លៃទាំងនេះលោកបានចងក្រងជាឯកសារមានចំណងជើងថា “កំណត់ហេតុស្តីពីទំនៀមទំលាប់ប្រទេសចេនឡា ” ហើយដែលបានប្រែជាភាសាបារាំងនៅឆ្នាំ១៨១៩ម្តងដោយលោក ARémusat និងនៅឆ្នាំ១៩០២ម្តងទៀតដោយលោក P -Pelliot. ។

នៅ ឆ្នាំ១២៩៥ព្រះបាទជ័យវរ្ម័នទី៨បានដាក់រាជ្យ ហើយផ្ទេរអោយព្រះអង្គម្ចាស់ **ស្រីន្ទ្រវរ្ម័ន** ដែលបានរៀបការជាមួយបុត្រីរបស់ព្រះអង្គនាម **ស្រីន្ទ្រភូបេស្វរចូឌា** ។ ប៉ុន្តែបើតាមសក្ខីភាពរបស់លោកជីវតាក្វាន់ដែលបានមកដល់នៅឆ្នាំបន្ទាប់(១២៩៦)ឃើញថា ការផ្លាស់ប្តូររជ្ជកាលនេះមានភាពឃោរឃៅណាស់ : "ស្តេចដែលឡើងសោយរាជ្យថ្មីគឺជាកូនប្រសាររបស់ស្តេចមុន ។ កូនស្រីរបស់ស្តេចអង្គនេះបានលួចយកព្រះខាន់មាសរបស់បិតាហើយយកទៅអោយស្វាមីនាង ។ ដូចនេះហើយបានជាកូនប្រុស ដែលត្រូវទទួលរាជសម្បត្តិបានរត់ទៅកើនទ័ព ។ ស្តេចថ្មីចាប់បានយកទៅកាត់ម្រាមជើងហើយយកទៅឃុំទុកក្នុងបន្ទប់ងងឹត " ។

ព្រះបាទជ័យវរ្ម័នទី៨បានទទួលមរណនាមថា **បរមេស្វរបទ** ។ ត្រង់នេះរឹតតែបញ្ជាក់អោយឃើញថាព្រះអង្គជាអ្នកទទួលខុសត្រូវធំក្នុងរឿងប្រតិកម្មប្រឆាំងនឹងពុទ្ធសាសនាក្នុងរជ្ជកាលរបស់ព្រះអង្គនោះឯង ។

## ២. ព្រះបាទស្រីន្ទ្រវរ្ម័ន (១២៩៥-១៣០៧)

នៅ ឆ្នាំ ១៣០៧ព្រះបាទ **ស្រីន្ទ្រវរ្ម័ន** ឬ **ឥន្ទ្រវរ្ម័នទី៣** បានដាក់រាជ្យផ្ទេរទៅអោយរជ្ជទាយាទ (យុវរាជ)ហើយយាងទៅគង់នៅក្នុងព្រៃ ។

គឺដោយសារស្តេចអង្គនេះហើយ ទើបមានការកសាងសិលាចារឹកជាភាសាបាលីជាលើកដំបូងនិយាយពីការស្ថាបនាព្រះវិហារមួយនិងព្រះពុទ្ធបដិមាមួយនៅ ឆ្នាំ១៣០៩ គឺ ២ឆ្នាំក្រោយដែលព្រះអង្គបានដាក់រាជ្យ ។

## ៣. ព្រះបាទស្រីន្ទជ័យវរ្ម័ន (១៣០៧-១៣២៧)

ស្តេចអង្គនេះ ត្រូវជាញាតិរបស់ស្តេចអង្គមុន ។ ព្រះអង្គទ្រង់យកព្រះនាមសំរាប់រាជ្យថា **ស្រីន្ទ្រជ័យវរ្ម័ន** ហើយបានសោយរាជ្យ២០ឆ្នាំ ។ ព្រះអង្គទ្រង់បានចាត់អោយគុបតែងបន្ថែមនូវប្រាសាទ (លេខ ៤៨៧) ដែលបានកសាងឡើងក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៨ ឧទ្ទិសចំពោះព្រាហ្មណ៍ជ័យមង្គលាថ៌ ។នៅឆ្នាំ១៣២០គណៈបេសកកម្មចិនមួយត្រូវបានបញ្ជូនមកដើម្បីទិញដីរឺផ្សាំងពីប្រទេសខ្មែរ ។

## ៤. ព្រះបាទជយវម៌ាទិបរមេស្វរ ឬ ជ័យវរ្ម័នទី៩ (១៣២៧...?)

នៅឆ្នាំ១៣២៧ ព្រះបាទ**ជយវម៌ាទិបរមេស្វរ**ឡើងសោយរាជ្យនៅអង្គរ ។ គេមិនដឹងច្បាស់ពីខ្សែញាតិដែលចងភ្ជាប់ស្តេចអង្គនេះទៅនឹងស្តេចសោយរាជ្យមុនៗទេ ។ ពត៌មានទាក់ទងនឹងព្រះអង្គបានមក

ពីសិលាចារឹក២ គឺសិលាចារឹកបាយ័ន(ខ្មែរ)និងសិលាចារឹកនៅអង្គរវត្ត(សំស្ក្រឹត) ។ សិលាចារឹកនេះជាស្នាដៃរបស់ព្រាហ្មណ៍ **ទិវាករបណ្ឌិត** ហើយជាសិលាចារឹកសំស្ក្រឹតចុងក្រោយបង្អស់ ។ ពោលពេញទៅដោយគំនិតសិវនិយម សិលាចារឹកនេះបានបង្ហាញអោយឃើញថា ទោះបីពុទ្ធសាសនាថេរវាទបានរីកសុះសាយណាស់ទៅហើយ ក៏ព្រាហ្មណ៍សាសនានៅតែបានទទួលសេចក្ដីអនុគ្រោះពីព្រះមហាក្សត្រនៅឡើយ ។

គេមិនដឹងច្បាស់ពីរយៈកាលដែលព្រះបាទជយវរ្ម័ទិបរមេស្វរ បានសោយរាជ្យនៅអង្គរទេ ។ តែគេអាចដឹងថាប្រាកដជាស្ដេចអង្គនេះហើយដែលបានបញ្ជូនទូតទៅប្រទេសចិននៅឆ្នាំ១៣៣០និងបានចាត់គណៈប្រតិភូមួយទៅធ្វើវន្ទនកិច្ចចំពោះប្រទេសដៃវៀតនៅច្រកភ្នំកឿវ៉ៅនៅឆ្នាំ ១៣៣៥ ។

# ច. ពីបដិវត្តន៍នាយត្រសក់ផ្អែមដល់ការបោះបង់ក្រុងអង្គរ

## ១. បដិវត្តន៍នាយត្រសក់ផ្អែម

ជ័យវរ្ម័នទី៩ ជាស្ដេចចុងក្រោយបង្អស់ដែលគេស្គាល់ដោយសិលាចារឹក ។ តពីនេះទៅប្រវត្តិ-សាស្ត្រខ្មែរត្រូវពឹងផ្អែកទៅលើរាជពង្សាវតារដែលជាឯកសារចងក្រងឡើងតែនៅស.វ.ទី១៨-១៩ ហើយដោយអាងទៅលើការទន្ទេញចាំមាត់និងលើអត្ថបទបូរាណខ្លះ ដែលពីដើមគេគំកល់ទុកនៅក្រុងឧដុង្គ ។ រាជពង្សាវតារមានច្រើនច្បាប់កត់ត្រាព្រឹត្តិការណ៍ដោយមានការដំណាលប្លែកៗគ្នា ហើយមានចុះការកំណត់ខុសៗគ្នាទៀត ។ នេះហើយជាហេតុនាំអោយអ្នកប្រវត្តិសាស្ត្រមានការលំបាកយ៉ាងខ្លាំងក្នុងការចងក្រងប្រវត្តិសាស្ត្រខ្មែរក្នុងសម័យចាប់តាំងពីក្រោយរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៩ ។

អាស្រ័យដោយហេតុដូចបានរៀបរាប់រួចមកហើយ អ្នកប្រវត្តិសាស្ត្រមានការអល់ឯកយ៉ាងខ្លាំងមិនដឹងថា ត្រូវដាក់ស្ដេចអង្គណាក្នុងរាជពង្សាវតារអោយសោយរាជ្យតពីជ័យវរ្ម័នទី៩ ដែលគេមិនទាំងដឹងថា បានសោយទីវង្គតនៅឆ្នាំណាផង ។ រួចមកហើយ អ្នកប្រវត្តិសាស្ត្រភាគច្រើននិយមដាក់នាយត្រសក់ផ្អែមអោយសោយរាជ្យតពីជ័យវរ្ម័នទី ៩ ព្រោះឯកសារជាច្រើនបានកត់ត្រាទុកថា បុគ្គលនេះបានឡើងសោយរាជ្យនៅប្រមាណឆ្នាំ១៣៤០ ។ ចំពោះរឿងនាយត្រសក់ផ្អែមនេះមានសេចក្ដីដំណាលខុសៗគ្នាទៅតាមក្បួនរាជពង្សាវតារ ប៉ុន្តែរឿងទាំងនោះមានចំណុចស្របគ្នាខ្លះដែលយើងអាចដកស្រង់បានដូចតទៅនេះ :

១. មានបុរសម្នាក់ដាំត្រសក់មានរស់ជាតិផ្អែម បានបេះផ្លែត្រសក់យកទៅថ្វាយស្ដេចហើយបានទទួលលំពែងសំរាប់ការពារត្រសក់របស់ខ្លួន ។

២. បានសម្លាប់ស្តេចដោយអចេតនានៅពេលយប់ ដោយស្មានថាជាចោលមកលួចផ្លែត្រសក់របស់ខ្លួន ។

៣. បាននាម៉ឺនសព្វមុខមន្ត្រីមូលមតិគ្នាលើកអោយឡើងសោយរាជ្យ ហើយលើកបុត្រីស្តេចអោយជាមហេសីទៀតផង ។

គួរកត់សំគាល់ថារឿងនាយត្រសក់ផ្អែមនេះ មានលំនាំប្រហាក់ប្រហែលនឹងរឿងព្រេងជាប់ទាក់ទងទៅនឹងរាជវង្សភូមាមួយនៅស. វ. ទី១០ ដែលមានសេចក្តីដំណាលជាសង្ខេបថា

នៅគ. ស. ៩៣១ អ្នកដាំត្រសក់ម្នាក់ឈ្មោះ **ញ៉ោងអ៊ូសូរ៉ះហាន** (Nyaung -u Sô-rahan) បានឡើងសោយរាជ្យនៅក្រុង **ប៉ុកាន** ក្រោយពីបានធ្វើគត់ស្តេចឈ្មោះ **សេងខូ** (Singho) ដែលបានលបលួចបេះត្រសក់របស់ខ្លួនក្នុងដំណើរធ្វើប្រមាញ់នៅក្នុងព្រៃហើយដែលខ្លួនពុំបានស្គាល់ថាជាស្តេចផែនដី ។

ម្យ៉ាងទៀត នៅមុនពេលបោះបង់ចោលក្រុងអង្គរ គេឃើញខ្មែរយើងមានប្រើពាក្យ **ពញា (ញ)** សំរាប់ហៅព្រះរាជបុត្រក្សត្រិយ៍ទ្រង់រាជ្យនិងមន្ត្រីជាន់ខ្ពស់ដូចពញាយ៉ាតជាដើម ។ គេបានសង្កេតឃើញថា ជនជាតិមនក្នុងបុរាណកាលក៏ធ្លាប់ប្រើពាក្យ **ពញា** នេះជាឋានន្តរសក្តិនៃមន្ត្រីជាន់ខ្ពស់ដែរ ។

នៅត្រង់នេះ អ្នកប្រវត្តិសាស្ត្របានចោទសួរថា តើរឿងព្រេងនៅស្រុកខ្មែរមានទំនាក់ទំនងយ៉ាងដូចម្តេចខ្លះជាមួយនិងរឿងព្រេងនៅប្រទេសភូមា ? ហើយកាលដែលខ្មែរប្រើពាក្យ **ពញា** នៅពេលនោះតើបណ្តាលមកពីហេតុអ្វីដែរ? ទោះបីពុំទាន់មានចម្លើយណាអោយបានសមរម្យ សំរាប់សំនួរទាំងនេះ ក៏ដោយក៏យើងអាចប៉ាន់ស្មានបានថា ប្រហែលជាធាតុទាំងនោះបាននាំចូលប្រទេសខ្មែរតាមរយៈពុទ្ធសាសនាហីនយានប្រើភាសាបាលី ដែលអ្នកស្រាវជ្រាវយល់ថា បានហូរចូលមកក្នុងជ្រោយសុវណ្ណភូមិភាគខាងលិចមុនគេគឺនៅត្រង់ម្តុំប្រទេសមន រួចផ្សាយចូលមកតំបន់វាលទំនាបទន្លេមេណាមរួចផ្សាយចូលបន្តមកក្នុងប្រទេសខ្មែរទៀត ។ លោកជីវតាក្វាន់ ទូតចិនដែលបានមកទស្សនាក្រុងអង្គរនៅចុងស. វ. ទី១៣ ក៏បានកត់សំគាល់ឃើញថា នៅសម័យនោះមានគេនិយមកាន់ច្រើនគ្នាណាស់ទៅហើយ ។ មានអ្នកប្រវត្តិសាស្ត្រខ្លះទៀតដូចជាលោក Adhémard Leclère និងលោក Dauphin Meunier ជាដើម យល់ថាព្រឹត្តិការណ៍នាយត្រសក់ផ្អែមឡើងសោយរាជ្យនៅក្រុងអង្គរនោះជាមហាបដិវត្តន៍មួយក្នុងប្រវត្តិសាស្ត្រខ្មែរ ហើយបដិវត្តិន៍នោះ គឺជាបដិវត្តិន៍ខាងនយោបាយនិងខាងសាសនា ។ តើពិតជាមាន បដិវត្តិន៍មែនឬយ៉ាងណា ? តើអ្វីខ្លះជាមូលហេតុនៃបដិវត្តន៍នោះ ?

យ៉ាងណាមិញ លិទ្ធិទេវរាជដែលព្រះបាទជ័យវរ្ម័នទី២ បានប្រារព្ធធ្វើជាលើកតំបូងនៅលើភ្នំគូលែននៅឆ្នាំ៨០២នោះ គឺជាអាវុធមួយយ៉ាងសក្តិសិទ្ធ ក៏ប៉ុន្តែអាវុធនោះជាអាវុធមុខពីរ បានសេចក្តីថា វា អោយផលល្អផងអោយផលអាក្រក់ផង ។ វាអោយផលល្អត្រង់ថា រាស្ត្រចាត់ទុកជ័យវរ្ម័នទី២ ជា

អាទិទេពមួយអង្គ ដោយបានធ្វើសន្និភាវូបនីយកម្មបង្រួមបង្រួមជាតិនិងដេញកំចាត់សត្រូវឈ្លានពាន អោយចេញពីទឹកដីខ្មែរ ម្ល៉ោះហើយរាស្ត្រក៏បាក់បបខ្លួបខ្លាចព្រះចេស្តា រួចរួមសាមគ្គីជុំវិញរាជបល្ល័ង្កធ្វើការកសាងជាតិអោយបានដល់ភាពរុងរឿង ត្រចះត្រចង់បំផុត ក្នុងប្រវត្តិសាស្ត្រខ្មែរ សមទៅតាមបំណងរបស់ស្តេច អាទិទេពដែលចង់បង្ហាញអោយរាស្ត្រឃើញថា លោកមានមហិទ្ធិរិទ្ធិពិតប្រាកដមែន ។ វាអោយផលអាក្រក់ត្រង់វាតម្រូវអោយមានការកសាងប្រាសាទថ្មកាន់តែធំឡើងហើយកាន់តែច្រើនឡើង ហើយស្រូបយកនូវកម្លាំង ពេលវេលា និងទ្រព្យសម្បត្តិច្រើនពេកពីរាស្ត្រ ដែលនៅទីបំផុតទៅរកតែផ្លូវគេចអោយផុតពីបន្ទុកនៃភាពរុងរឿងរបស់ព្រះមហាក្រក្សត្រខ្លួនហើយរត់ទៅជ្រកក្រោមម្លប់ដ៏ត្រជាក់នៃព្រះពុទ្ធសាសនាថេរវាទដែលប្រៀនប្រដៅអោយមនុស្សលោកលះបង់អ្វីៗទាំងអស់ដើម្បីឈោងចាប់យកនិព្វានជាទីបរមសុខ ។

បើតាមពិនិត្យមើលទៅឃើញថា ទំនាស់ក្នុងផ្លូវសាសនានេះមានយូរណាស់មកហើយគឺតាំងពីក្នុងរជ្ជកាលឧទយាទិត្យវរ្ម័នទី២ម្ល៉េះ(១០៥០-១០៦៦)ដោយនៅពេលនោះ គេឃើញមានការបះបោរបីលើកហើយក្នុងចលនាទាំងនោះ ពួកបះបោរបានវាយកំទេចសិវលិង្គនិងបដិមាផ្សេងៗខាងព្រាហ្មណ៍សាសនាផង ។ ឯពុទ្ធសាសនាឃើញថាមានការចំរើនលូតលាស់កាន់តែខ្លាំង ជាពិសេសក្នុងរជ្ជកាលរបស់ព្រះបាទ ធរណីន្ទ្រវរ្ម័នទី ២(១១៥៥-?) និងព្រះបាទជ័យវរ្ម័នទី៧(១១៨១-១២១៨?)រហូតដល់មានប្រតិកម្មយ៉ាងខ្លាំងក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៨ ពីសំណាក់អ្នកកាន់ពុទ្ធសាសនាព្រាហ្មណ៍ ។ ដូច្នេះយើងឃើញថា វិបត្តិខាងសាសនាកាន់តែរីកធំឡើង ដោយបន្ទាប់ពីនោះមានស្តេចខ្លះក៏ត្រឡប់ទៅកាន់ពុទ្ធសាសនាវិញ ហើយជាពុទ្ធសាសនាថេរវាទថែមទៀត ដែលព្រះអង្គម្ចាស់តាមលិន្ទបាននាំចូលស្រុកខ្មែរប្រហែលតាំងពីរជ្ជកាលឥន្ទ្រវរ្ម័នទី២មកម្ល៉េះ ហើយក៏មានស្តេចខ្លះត្រឡប់ទៅកាន់សាសនាព្រាហ្មណ៍វិញដែរ រហូតដល់រជ្ជកាលរបស់នាយត្រសក់ផ្អែម និងកូនចៅរបស់គាត់ដែលសោយរាជ្យតរៀងមក ទើបស្តេចខ្មែរកាន់ជាប់តែពុទ្ធសាសនារហូតដល់សព្វថ្ងៃ ។ ត្រង់នេះហើយជាហេតុនាំអោយអ្នកប្រវត្តិសាស្ត្រខ្លះយល់ថា កាលដែលនាយត្រសក់ផ្អែមធ្វើគត់ស្តេចហើយបាននាម៉ឺនសព្វមុខមន្ត្រីលើកអោយឡើងសោយរាជ្យ ជាបដិវត្តន៍ដណ្តើមយកអំណាចនយោបាយនិងអំណាចសាសនាដែលនៅជាប់គ្នា ព្រោះក្នុងសម័យនោះអំណាចទាំងពីរស្ថិតនៅក្នុងការកាន់កាប់ របស់ព្រះមហាក្សត្រទាំងអស់ ។

## ២. ចម្បាំងលើកទី ២ជាមួយសៀម :

ក្រោយពីព្រះបាទត្រសក់ផ្អែមសោយទីវង្គតទៅ បុត្ររបស់ព្រះអង្គព្រះនាម **និព្វានបទ** បានឡើងសោយរាជ្យស្នងពីឆ្នាំ១៣៤០ដល់១៣៤៦និងចៅរបស់ព្រះអង្គ(បុត្រព្រះបាទនិព្វានបទ)ព្រះនាម **លំពង់រាជា** បានទទួលរាជសម្បត្តិពីឆ្នាំ ១៣៤៦ដល់១៣៥១ ។ នៅឆ្នាំ១៣៥១ស្តេចសៀមព្រះនាម **រាមាធិបតី**

ក្រោយពីបានតាំងរាជធានីនៅក្រុង**អយុធ្យា** ហើយលើកទ័ពចូលមកវាយខ្មែរ ។ តែមុននឹងមកដល់អង្គរ ទ័ពសៀមត្រូវឧបរាជខ្មែរ (**សុយោធ័យ**អនុជលំពង់រាជា)លើកទ័ពទៅស្កាត់វាយបាក់ ទ័ពថយទៅវិញអស់ ។ ព្រះលំពង់រាជានិកស្មានថាសត្រូវពុំអាចធ្វើអ្វីបានទៀតក៏ទ្រង់បញ្ជារំសាយកងទ័ពអោយទៅកាន់ទីលំនៅរៀងៗខ្លួនវិញ ។ លុះឮថាសៀមលើកទ័ពចូលមកជាថ្មីម្តងទៀត ខ្មែរកែនទ័ពមិនទាន់ក៏ដេញរាស្ត្រអោយចូលក្នុងកំពែងមហានគរហើយកែនពលអោយការពារ ។ ទ័ពសៀមមកលោមព័ទ្ធជុំជិតអស់រយៈពេល១ឆ្នាំ៥ខែ ។ ទ័ពជំនួយខ្មែរជាច្រើនបានលើកពីកន្លែងផ្សេងៗតែដោយមកមិន ស្មើគ្នាក៏ត្រូវទទួលបរាជ័យ ។ ឯខាងសៀមក៏ចេះតែបញ្ជូនទ័ពមកជាបន្ថែម ។ ព្រះលំពង់រាជាក៏សោយ ទីវង្គតដោយរោគ ។ សៀមវាយលុកចូលកាន់តែខ្លាំង ហើយនៅទីបំផុតមេទ័ពសៀម **បាសាត** វាយទំលាយបានទ្វារខាងកើត ។ ការប្រយុទ្ធគ្នាក៏មានបន្តទៅទៀតនៅក្នុងក្រុង ជាហេតុនាំអោយព្រះឧបរាជ**ស្រីសុរិយោធ័យ** ក៏សុគតទៅទៀត ។ ក្នុងគ្រានោះស្តេចនិងរាជគ្រូបុរោហិតបាននាំយកគ្រឿងសំរាប់រាជ្យវាយទំលាយទ័ពសៀមរត់រួចចេញទៅ ។ ប៉ុន្តែរាជធានីអង្គរត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់សៀមនៅឆ្នាំ១៣៥២ ។

ក្រោយពីបានអភិសេកបុត្រនាម **ចៅបាសាត** អោយឡើងសោយរាជ្យនៅក្រុងអង្គរនិងតែងតាំងចៅហ្វាយខេត្តជាតិសៀមអោយត្រួតត្រាខេត្តខ្មែរទាំងឡាយនៅខាងលិច ដែលគេយកបានក្នុងដំណើរវាយលុកចូលក្រុងអង្គរព្រះចៅរាមាធិបតីទ្រង់បានត្រឡប់ទៅក្រុងអយុធ្យាវិញដោយបានកៀររាស្ត្រយកទៅជាឈ្លើយនិងដឹកជញ្ជូនទ្រព្យសម្បត្តិអស់ជាច្រើនទៀតផង ។

បុត្ររបស់ព្រះចៅរាមាធិបតីទាំង៣ គឺ **បាសាត បាអាត** និង**កំបង់ពិសី** បានឡើងសោយរាជ្យជាបន្តបន្ទាប់គ្នានៅក្រុងអង្គរពីឆ្នាំ១៣៥២ដល់១៣៥៧ ។ ពេលនោះព្រះ **សុរិយោវង្ស** អនុជព្រះលំពង់រាជាដែលបានភៀសព្រះអង្គទៅប្រទេសលាវ **លានជាង** នោះបានលើកទ័ពមកវាយយកបាន ក្រុងអង្គរនៅឆ្នាំ១៣៥៧ ។ ចៅកំបង់ពិសីត្រូវសុគតក្នុងសង្គ្រាម ។ បន្ទាប់មកខ្មែរក៏បានវាយកំចាត់សៀមអោយចេញផុតពី **នគររាជសីមា** នៅទិសពាយ័ព្យនិង **ចន្ទបុរី** នៅទិសនិរតី ។ ព្រះបាទសុរិយោវង្សបានសោយទីវង្គតនៅឆ្នាំ១៣៦៣ដោយរោគា ។ ក្មួយរបស់ព្រះអង្គព្រះនាម **បរមរាមា** បានឡើងសោយរាជ្យស្នងពីឆ្នាំ ១៣៦៣ដល់១៣៧៣ ។ ព្រះអង្គបានចងស្ពានមេត្រីជាមួយព្រះចៅ **ហុងវ៉ូ** នៃរាជវង្សមិង ។ ឯជនជាតិសៀមក៏ពុំបានមកឈ្លានពានខ្មែរទៀតទេ ដោយជាប់ដៃក្នុងការប្រយុទ្ធជាមួយក្សត្របុរីជាច្រើននៅខាងជើងក្រុងអយុធ្យា ។

## ៣. ចម្បាំងលើកទី៣ជាមួយសៀម

ស្តេចដែលឡើងសោយរាជ្យនៅឆ្នាំ១៣៧៣គឺព្រះបាទ **ធម្មាសោក** ជាព្រះអនុជព្រះបរមរាមា ។ គ្រានោះ នៅប្រទេសសៀមស្តេច **រាមាសូរ** បានឡើងសោយរាជ្យ ហើយក៏បន្តនយោបាយពង្វាតទឹកដី

របស់រាមាធិបតីមកលើទឹកដីខ្មែរ ។ ក្រុងអង្គរត្រូវលោមព័ទ្ធសាជាថ្មីអស់រយៈពេល៧ខែ (ពីខែមិគសិរ ដល់ខែជេស្ឋ) ។ ដោយឃើញថាមិនអាចប្រយុទ្ធយកជ័យជំនះលើខ្មែរដោយកម្លាំងអាវុធបានទើបសៀម ប្រើឧបាយកលម្តងវិញ ។ ទាហានសៀមចំនួន១៥នាក់ បានធ្វើកលសុំចុះចូលខាងខ្មែរដោយយកលេស ថា ស្តេចសៀមធ្វើបាបខ្លួនខ្លាំងពេក ព្រោះតែខ្លួនច្បាំងមិនឈ្នះខ្មែរ ។ នៅទីបំផុតពួកនេះបានរកមធ្យោបាយបើកទ្វារខាងលិចបាន ។ ក្រុងអង្គរក៏ត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃសៀមជាលើកទី២ (១៣៩៣) ។ ឯព្រះបាទធម្មាសោកក៏បានសោយទីវង្គតនៅពេលដែលសៀមហ៊ុំព័ទ្ធក្រុងអង្គរនោះទៅ ។

ព្រះចៅសៀមបានអភិសេកបុត្រឈ្មោះ **ពញាវ៉ៃព្រែក** អោយឡើងសោយរាជ្យនៅឆ្នាំ១៣៩៤ **(ឥន្ទរាជា)** រួចដឹកជញ្ជូនទ្រព្យសម្បត្តិនិងកៀរឈ្លើយខ្មែរ ៧០០០០នាក់ត្រឡប់ទៅក្រុងអយុធ្យាវិញ ។

គ្រានោះ **ពញាយ៉ាត** ជាបុត្រសុយោវង្សបានរត់រួច ហើយទៅកែនទ័ពតាំងមូលដ្ឋាននៅទួលបាសាន ។ ចលនារំដោះជាតិដឹកនាំដោយស្តេចអង្គនេះមានការរីកចំរើនឆាប់រហ័សណាស ។ តែប្រាំខែក្រោយមកទ័ពខ្មែរមានសមត្ថភាពអាចលើកមកវាយរំដោះយកបានក្រុងអង្គរវិញ ។ តែមុននឹងទ័ពធំចូលមកដល់ពញាយ៉ាតបានបញ្ជាអោយទាហានស្ម័គ្រចិត្ត១២នាក់ធ្វើកលទៅសំចុះចូលជាមួយនឹងស្តេចសៀម ហើយដកអាវុធធ្វើគត់ស្តេចសៀមនៅនឹងកន្លែងតែម្តង ។ លុះវាយរំដោះបានរាជធានីហើយពញាយ៉ាតក៏យកស្រីសៀមឈ្មោះ **ស៊ីសាខាម** ជាប្អូនជីដូនមួយរបស់ស្តេចសៀមធ្វើជាស្នំឯងហើយឡើងសោយរាជ្យនៅក្រុងអង្គរជាសុខសាន្តរៀងមកដោយមាននមរណនាមថា **រាជឱង្ការព្រះបរមរាជាធិរាជ** ។

## ៤. ការបោះបង់ចោលក្រុងអង្គរ

នៅឆ្នាំ១៤៣១ដោយចេះតែរអែងខ្លាចសៀមចូលមកលុកលុយប្រទេសខ្មែរទៀតព្រះបាទពញាយ៉ាតក៏បានសំរេចព្រះទ័យលើករាជធានីចេញអោយឆ្ងាយពីអង្គរ ។ មូលហេតុនៃការបោះបង់ចោលក្រុងអង្គរនេះគឺមកពីប្រជារាស្ត្រខ្មែរនៅអាណាខេត្តខាងលិចត្រូវសៀមកៀរយកទៅអស់ជាច្រើន ហើយមួយផ្នែកទៀតត្រូវស្លាប់ ដោយសង្គ្រាមជាច្រើនលើកច្រើនគ្រាជាមួយសៀមទៀត ម្ល៉ោះហើយឃើញថាមានមនុស្សតិចពេកមិនអាចការពាររាជធានីអង្គរតទៅទៀតដែលពេលនោះស្ថិតនៅប្រមាណតែ ៤០០គម. ពីក្រុងអយុធ្យាតែប៉ុណ្ណោះ ។

ក្រោយពីបានប្រឹក្សាសួរយោបល់ពីនាម៉ឺនសព្វមុខមន្ត្រីហើយ ព្រះបាទពញាយ៉ាតក៏ទ្រង់បញ្ជាអោយលើករាជធានីទៅតាំងនៅ **ទួលបាសាន**ក្នុងខេត្តស្រីសឈរវិញ ។ តែដោយមានទឹកជំនន់ធំខុសធម្មតា ព្រះអង្គក៏បញ្ជាអោយលើករាជធានីពីទួលបាសានទៅតាំងនៅ **ភ្នំដូនពេញ ចតុមុខ** វិញ ។

## ឆ. អរិយធម៌ខ្មែរសម័យអង្គរ

នៅសម័យអង្គរខ្មែរមានឈ្មោះថាជាមហាអំណាចមួយនៅអាស៊ីអគ្នេយ៍ ។ យ៉ាងណាមិញអរិយ-ធម៌ខ្មែរបានឡើងដល់កំរិតកំពូលនៅសម័យនោះ ជាពិសេសចាប់ពីស. វទី៩ ដល់ដើមស. វ. ទី ១៣ ។ ភាពរុងរឿងនេះគេអាចសំគាល់ដោយផ្ទៃដីធំទូលាយ លាតសន្ធឹងសឹងតែអស់ផ្ទៃដីឥណ្ឌូចិនទាំងមូល ដោយប្រាសាទសិលាមានចំនួនច្រើនរាប់ពាន់ប្រកបដោយក្បាច់រចនាគួរអោយកោតស្ញប់ស្ញែងដោយផ្ទាំងសិលាចារឹកច្រើនសន្ធឹកសន្ធាប់ មានទាំងភាសាសំស្ក្រឹត និងខ្មែរបុរាណឬជួនកាលមានភាសាទាំងពីរលាយចំរុះគ្នាដោយរូបបដិមាគ្រប់ប្រភេទនិងបុរាណវត្ថុផ្សេងៗទៀត និងជាពិសេសដោយបរិក្ខារសង្ខរណ ដែលមានសេសសល់រហូតមកដល់សព្វថ្ងៃដូចជា បារាយ ទំនប់ទឹក បណ្ដាញជលគតិ ផ្លូវថ្នល់ស្ពាន ។ ល ។ ប៉ុន្តែចាប់ពីពាក់កណ្ដាលទី១នៃស. វ. ទី១៣ ទៅការចុះដុនដាបក៏ចាប់មានបន្តិចម្ដងៗរហូតដល់ត្រូវបោះបង់រាជធានីអង្គរចោលនៅស. វទី១៥ ដោយព្រះបាទចៅពញាយ៉ាត ។ តទៅនេះយើងសាកល្បង បង្ហាញរូបភាព(តាមដែលអាចធ្វើបាន)នៃសង្គមខ្មែរក្នុងសម័យដ៏រុងរឿងនោះ ។

### ១. នយោបាយនិងរដ្ឋបាល

#### ១.១. ព្រះរាជា

ដោយការប្រារព្ធធ្វើពិធីទេវរាជ ព្រះរាជាត្រូវមានឋានៈស្មើអាទិទេព ។ លុះសោយទីវង្គតទៅព្រះអង្គនិងយាងទៅគង់នៅទេវលោក ។ រាជធានីរបស់ព្រះអង្គជាតំណាងនៃចក្រវាលទាំងមូលៈ ប្រាសាទភ្នំនៅកណ្ដាលក្រុងជានិមិត្តរូបភ្នំព្រះសុមេរុ ដែលគេចាត់ទុកថាជាស្នូលនៃចក្រវាល កំពែងនិងគូទឹកជានិមិត្តរូបជួរភ្នំនិងសមុទ្រដែលព័ទ្ធជុំវិញភ្នំព្រះសុមេរុ ។ ប្រាសាទភ្នំសំរាប់តំកល់លិង្គទេវរាជ អាចប្រើបានសំរាប់តែព្រះរាជាមួយអង្គប៉ុណ្ណោះ លុះព្រះអង្គសោយទីវង្គតទៅប្រាសាទនោះនឹងក្លាយជាផ្នូររបស់ព្រះអង្គ ។

លោកជីវតាក្វាន់ដែលបានមកទស្សនាប្រទេសខ្មែរនៅចុងស. វ. ទី១៣បានធ្វើការពិពណ៌នាពីការយាងចេញរបស់ព្រះរាជា ដែលគួរអោយយើងចាប់អារម្មណ៍យ៉ាងខ្លាំង ។ នៅមុខក្បួនដង្ហែមានពួកទាហានបន្ទាប់មកមានអ្នកកាន់ទង់ជ័យនិងអ្នកភ្លេង ។ បន្ទាប់មកទៀត គឺពួកស្រីៗដែលមានគ្នាពីបី ។ រយទៅប្រាំរយនាក់ មានសំលៀកបំពាក់ប្រកបដោយកំណាត់មានភ្ញីស្លឹកឈើ មានផ្កាសៀតក្នុងផ្នួងសក់ដៃកាន់ទៀនដែលនៅពេលថ្ងៃក៏ត្រូវអោយឆេះដែរ ។ តមកទៀតមានស្រីៗមួយពួកផ្សេងទៀតកាន់គ្រឿងប្រដាប់ស្ដេចធ្វើពីមាសនិងប្រាក់និងគ្រឿងលំអទាំងអស់សុទ្ធសឹងតែជារបស់ប្លែកៗ ។ តពីនោះ

មានស្រីៗមួយពួកទៀតដែលជារាជអង្គរក្សដើរកាន់លំពែងនិងខែល ។ តមកទៀតគឺរទេះពពែ រទេះសេះ ដែលសុទ្ធសឹងតុបតែងដោយគ្រឿងមាស ។ ពួកក្សត្រ និងពួកនាម៉ឺនសព្វមុខមន្ត្រីសុទ្ធតែជិះដំរី ដែលគេមើលពីចម្ងាយមកឃើញតែក្លស់ពណ៌ក្រហមច្រើនសន្ធឹកសន្ធាប់ ។ បន្ទាប់ពីពួកនេះ គឺមហេសី និងស្នំរបស់ព្រះរាជាដែលជិះគ្រែស្នែង រទេះសេះ និងដំរី ហើយមានក្លស់ជាងមួយរយលាបទឹកមាស ។ ចុង ក្រោយបង្អស់គឺព្រះរាជាដែលគង់ឈរលើដំរីហើយទ្រង់កាន់ព្រះខាន់ ។ ភ្លុកដំរីនេះសុទ្ធសឹងតែស្រោបមាសដែរ ។ ឯក្លស់បាំងព្រះរាជាមានជាងម្ភៃ ជាក្លស់សចំរុះពណ៌មាស ហើយមានដងក៏ស្រោបមាសទៀត ។ មានដំរីដទៃទៀតជាច្រើនដើរអមដំណើរព្រះអង្គ ហើយមានទាហានដទៃទៀតតាមការពារព្រះអង្គ ។ ជនណាដែលឃើញព្រះរាជាហើយត្រូវតែលុតជង្គង់ហើយអោនក្បាលដល់ដី (30) ។



*ក្បួនដង្ហែរព្រះរាជា*

## ១.២. អំណាចព្រះរាជា

ដោយលទ្ធិទេវរាជអំណាចរបស់ព្រះរាជាមានប្រភពចេញមកពីអាទិទេព ។ ព្រះអង្គមានអំណាចលើដីធ្លីទាំងអស់ : ការលក់ ការប្តូរ ឬ ការធ្វើអំណោយដី ត្រូវតែមានសេចក្តីយល់ព្រមពីព្រះអង្គទើប

បាន ។ ព្រះរាជាមានអំណាចទូលំទូលាយណាស់ ៈ ព្រះអង្គជាអ្នកធ្វើច្បាប់ ជាអ្នកជ្រើសរើសមន្ត្រីជាន់ខ្ពស់ជាអគ្គបញ្ជាការនៃកងទ័ព ជាអ្នកកាន់កាប់នយោបាយក្រៅប្រទេស (ពួករាជទូតបរទេសត្រូវមកបង្គំគាល់ចំពោះព្រះអង្គ) ជាអ្នកកាត់សេចក្តី (ប្រសិនបើរាស្ត្រណាចង់) ជាមេសាសនា(តែងតាំងពួកបព្វជិតជាន់ខ្ពស់និងធ្វើអធិបតីក្នុងពិធីសាសនាផ្សេងៗ)ជាអ្នកការពារប្រទេសមិនអោយសត្រូវយាយីពីខាងក្រៅ និងរាប់រងអោយមានសន្តិភាពនៅខាងក្នុង ។ គួរគត់សំគាល់ថាព្រះរាជាមិនគ្រាន់តែមាននាមថា ជាអគ្គបញ្ជាការតែប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គជាមេទ័ពដឹកនាំទ័ពចេញទៅប្រយុទ្ធជាមួយសត្រូវនៅក្នុងសមរភូមិតែម្តង ។ អត្ថបទសិលាចារឹកជាច្រើនបានកោតសរសើរចំពោះគុណសម្បត្តិយោធារបស់ព្រះរាជាថា សុទ្ធសឹងតែមានតេជដៃខ្លាំងពូកែមានជ័យជំនះលើសត្រូវជានិច្ច ។ នេះជាគំរាប់ល្អមួយសំរាប់ពលទាហានដែលកាន់តែមានចិត្តក្លាហានក្នុងការប្រយុទ្ធការពារទឹកដីក្តី ក្នុងចំបាំងវាតអំណាចវាតទឹកដីតាមលទ្ធិទេវរាជក្តី ។ រូបចម្លាក់លើជញ្ជាំងប្រាសាទ (អង្គរវត្ត និងបាយ័ន) បានបង្ហាញអោយឃើញថាទ័ពខ្មែរជំនាន់នោះមានពលថ្មើរជើងពលសេះ ពលដំរីនិង ពលជើងទឹកនិងបង្ហាញអោយឃើញថាមានពលសំរាប់ផ្តល់សៀ្បងថែមទៀតផង ។ ម្យ៉ាងទៀតបើតាមរូបចម្លាក់ដដែលនោះឃើញថាទ័ពខ្មែរសម័យនោះច្បាស់ជាមានរបៀបរៀបរយនិងវិន័យថ្លៃថ្នូរណាស់ ។ សិលាចារឹកវិញបានបញ្ជាក់ថាការបះបោរទាំងឡាយត្រូវបានបង្ក្រាបយ៉ាងតឹងរ៉ឹងជាទីបំផុត ឯទាហានដែលមានគុណបំណាច់ចំពោះជាតិត្រូវបានលើកតំកើងជាអតិបរមា (ករណីសញ្ញកទាំង៤របស់ស្រីន្ទកុមារ បុត្រជយវរ្ម័នទី៧)ដោយមានការកសាងរូបបដិមា និងប្រាសាទសំរាប់រំលឹកគុណ ។

ការដែលបង្ហាញអោយឃើញថា ព្រះរាជាសម័យអង្គរមានអំណាចទូលំទូលាយនោះ ពុំមែនមានន័យថាព្រះអង្គជាអ្នកកាន់អំណាចផ្តាច់ការទេ ព្រោះព្រះអង្គត្រូវគោរពវិន័យវណ្ណៈក្សត្រិយ៍ គោរពសិក្ខាបទសាសនា បានសេចក្តីថាព្រះអង្គត្រូវប្រកបដោយទសពិធរាជធម៌ ។ សិលាចារឹកព្រះគោ ស្លោកទី៣ បាននិយាយពីព្រះបាទឥន្ទ្រវរ្ម័នទី១ថាៈ "ស្រីឥន្ទ្រវរ្ម័នធ្វើអោយប្រជារាស្ត្រសម្បូណ៏សប្បាយដោយការប្រតិបត្តិនូវវិន័យទាំង ៣ប្រការ " ។ ចំពោះប្រជារាស្ត្រ ព្រះរាជាតែងមានព្រះហឬទ័យអាណិតមេត្តានិងប្រកបដោយយុត្តិធម៌ជានិច្ច ។ ព្រះបាទជយវរ្ម័នទី៧ទ្រង់បានខិតខំធ្វើអោយបានសំរេចឧត្តមគតិនេះដោយបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីព្រះពុទ្ធសាសនា ។ សិលាចារឹកមន្ទីរពេទ្យរបស់ព្រះអង្គបានថែងថាៈ "ជម្ងឺរបស់ប្រជារាស្ត្រធ្វើអោយព្រះអង្គឈឺចាប់ជាងជម្ងឺផ្ទាល់ព្រះអង្គទៅទៀត ព្រោះថាគឺសេចក្តីឈឺចាប់សាធារណៈនេះហើយជាសេចក្តីឈឺចាប់របស់ព្រះរាជាទាំងឡាយ ពុំមែនសេចក្តីឈឺចាប់ផ្ទាល់ទេដែលធ្វើអោយព្រះអង្គឈឺចាប់ " ។

## ១.៣. ការបន្តរាជសម្បត្តិ

បើតាមគោលការណ៍ បុត្រច្បងអាចឡើងសោយរាជ្យស្នងព្រះបិតា ប៉ុន្តែបើគ្មានបុត្រទេញាតិណាម្នាក់អាចឡើងសោយរាជ្យបាន ។ ចំពោះការបន្តរាជសម្បត្តិនេះ មានមតិពីរផ្ទុយគ្នា :អ្នកខ្លះយល់ថាមានតែញាតិជាប់ខ្សែខាងស្រីទៅនឹងព្រះរាជាទើបអាចឡើងស្នងរាជ្យបាន អ្នកខ្លះទៀតយល់ផ្ទុយទៅវិញ ប៉ុន្តែបានបញ្ជាក់ថាទាល់តែជាប់ញាតិខ្សែខាងស្រីជាមួយស្តេចមុនឬត្រូវយកក្សត្រីស្ត្រីណាមួយក្នុងគ្រួសារស្តេចមុន ទើបអាចទទួលរាជសម្បត្តិបាន(40) ។ ក្នុងករណីដែលព្រះរាជាទទួលរាជសម្បត្តិហើយនៅតែក្មេងពេក នោះកិច្ចការរដ្ឋត្រូវបានព្រះគ្រូជាអ្នកទទួលខុសត្រូវ ។

## ១.៤. ពួកបរិវារ

រូបចម្លាក់លើជញ្ជាំងប្រាសាទអង្គរវត្ត បង្ហាញព្រះបាទសូរ្យវរ្ម័នទី២ គង់លើបល្លង្កទទួលគារវកិច្ចពីពួកបរិវារ ដែលមានជាអាទិពួករាជវង្សានុវង្ស មន្ត្រីជាន់ខ្ពស់ទាំងខាងស៊ីវិលនិងខាងទាហាន និងបុគ្គលិកមួយចំនួនច្រើនសន្ធឹកសន្ធាប់ណាស់ ។

ព្រះរាជាគង់នៅក្នុងវាំងសង់ពីឈើ ។ លោកជីវតាក្វាន់មានការស្ងប់ស្ងែងយ៉ាងខ្លាំងចំពោះភាពរុងរឿង និងប្រណីតភាពនៃរាជវាំងនេះ ជាពិសេសចំពោះសាលសវនាការដែលមានបង្អួចមាស ហើយនៅខាងស្តាំនិងខាងឆ្វេងមានសសរបួនជ្រុងមានដាំកញ្ចក់តំរៀបគ្នា ។ ល ។

## ១.៥. រដ្ឋបាល

### *រដ្ឋបាលកណ្តាល*

ការគ្រប់គ្រងរដ្ឋត្រូវស្ថិតនៅក្នុងកណ្តាប់ដៃរបស់អភិជនមួយក្រុមតូច ។ តំណែងធំៗត្រូវបានទៅរាជវង្សានុវង្ស ឯតំណែងជាបុរោហិត អ្នកប្រារព្ធពិធីនៃទេវរាជ ព្រះរាជគ្រូត្រូវបានទៅសមាជិកត្រកូលព្រាហ្មណ៍ខ្លះដែលនិយមការបន្តតំណែងដោយរាប់ញាតិតាមខ្សែស្រី ។

វណ្ណៈក្សត្រិយ៍ និងវណ្ណៈព្រាហ្មណ៍ជាវណ្ណៈខ្ពស់ស្ថិតដាច់ពីវណ្ណៈរាស្ត្រទូទៅគឺជាវណ្ណៈបញ្ញវន្តនិងជាតំណាងអរិយធម៌ឥណ្ឌា ។ វណ្ណៈកំពូលទាំងពីរនេះច្រើនចងសម្ព័ន្ធមេត្រីជាមួយគ្នា ។

ព្រះរាជាទ្រង់ប្រទានសវនាការពីរដងក្នុងមួយថ្ងៃ សំរាប់ដោះស្រាយកិច្ចការរដ្ឋ ។ ពួកនាម៉ឺនឬពួកប្រជារាស្ត្រដែលមានការចូលមកបង្គំគាល់ត្រូវរង់ចាំព្រះអង្គដោយអង្គុយផ្ទាល់ដី ។ ពេលដែលព្រះអង្គយាងមកដល់ទាំងមន្ត្រីទាំងប្រជារាស្ត្រត្រូវលើកដៃប្រណម្យហើយអោនក្បាលដល់ដី ។



*ព្រះរាជាប្រទានសវនាការ*

នៅក្នុងរដ្ឋបាលកណ្តាល គេឃើញមានមន្ត្រីច្រើនៈ មន្ត្រីជាន់ខ្ពស់ខ្លះមានមុខងារជាទីប្រឹក្សាខ្លះទៀតទទួលបន្ទុកធំៗនៅក្នុងវាំងឬកាន់ទ័ពនិងឈរត្រួតនៅតាមខេត្តខណ្ឌ ឯមន្ត្រីជាន់ទាបត្រូវបានជ្រើសរើសដោយមន្ត្រីជាន់ខ្ពស់ហើយមាននាទីនៅបំរើពួកនេះ ។ សញ្ញាសក្តិគេសំគាល់ដោយប្រភេទក្រែស្នែង(មាស ឬ ប្រាក់)និងចំនួនក្លស់(ដងមាស ឬ ដងប្រាក់) ។

## *រដ្ឋបាលភូមិភាគ*

នៅក្នុងរដ្ឋបាលភូមិភាគ គេឃើញមានមន្ត្រីច្រើនជាន់ច្រើនថ្នាក់ទៀតគឺមានតាំងពីអធិការ(អាជ្ញាហ្លួង?) ចៅហ្វាយខេត្ត មេស្រុក មេភូមិ មេឃ្លាំង មេខ្នង(?) មេត្រួត(មេការ?) ។ ល ។ ស្ត្រីក៏មានមុខងារសំខាន់ណាស់ដែរៈ ខ្លះធ្វើជាហោរាខ្លះទៀតធ្វើជាចៅក្រមក្នុងរាជវាំង ។

ចំពោះការធ្វើសច្ចាប្រណិធានរបស់មន្ត្រី ថាស្មោះត្រង់ចំពោះព្រះមហាក្សត្រនោះ គេមិនដឹងថានេះជាវិធានការទូទៅឬគ្រាន់តែជាមធ្យោបាយសំរាប់ចងភ្ជាប់មន្ត្រីទៅនឹងព្រះរាជាកាលណាឡើងសោយរាជ្យមិនស្របច្បាប់ ?

## ២. សាសនានិងលទ្ធិផ្សេង ៗ

### ២.១. សាសនា

នៅសម័យអង្គរ សាសនាមានមុខងារយ៉ាងសំខាន់ក្នុងនយោបាយប៉ុន្តែសាសនានៃវណ្ណៈអ្នកដឹកនាំពុំដែលមានឯកភាពទេ គឺតែងផ្លាស់ប្តូរទៅតាមចំណូលចិត្តរបស់បុគ្គលម្នាក់ៗៈ ព្រះរាជាខ្លះកាន់សាសនាឥសូរ ព្រះរាជាខ្លះកាន់សាសនាព្រះវិស្ណុ ព្រះរាជាខ្លះកាន់សាសនាព្រះព្រហ្មនិងខ្លះទៀតកាន់ព្រះពុទ្ធសាសនា ។ ចំពោះហេតុការណ៍បែបនេះ លោក Sylvain Lévi ថា គឺកើតមកពីរចនាសម្ព័ន្ធនៃសង្គមខ្មែរតែម្តង ។ យ៉ាងណាមិញ នៅសម័យនោះសាសនាត្រូវគេចាត់ទុកដូចទំនិញដែលគេនាំចូលឬជាវប្បធម៌ថ្លៃថ្នូរសំរាប់តែព្រះរាជានិងពួកអភិជន ហើយមិនសូវជ្រួតជ្រាបចូលក្នុងស្រទាប់ទាបៗនៃ សង្គមដែលនៅតែថែរក្សាជំនឿដើមគឺជំនឿលើអារក្សអ្នកតាជាដើម ។លោកជីវតាក្វាន់កាលមកស្រុកខ្មែរបានសង្កេតឃើញថា មានមនុស្សគោរពដុំថ្មដែលលោក Paul Pelliot ស្មានថា ជាលិង្គព្រះឥសូរតែតាមការពិតគឺថ្មអ្នកតានេះឯង ។

ពីស.វ.ទី ៩ ដល់១១ គណៈសិវនិយមមានឧត្តមភាពលើគណៈឯទៀតៗ ព្រោះព្រះរាជាភាគច្រើនបានចាត់ទុកថាជាសាសនាសំរាប់រដ្ឋដោយការប្រារព្ធធ្វើពិធីទេវរាជព្រះរាជាមានឋានៈស្មើអាទិទេព (ព្រះឥសូរ) ហើយមានសិវលិង្គជាតំណាងតំកល់ក្នុងប្រាសាទភ្នំ ។ ប៉ុន្តែក្នុងរយៈពេលខាងលើនេះ គេបានសង្កេតឃើញថា ព្រះរាជាទាំងឡាយតែងបានយកព្រះហឫទ័យទុកដាក់ និងជួយឧបត្ថម្ភចំពោះសាសនាឯទៀតដែលបានរួមរស់ជាមួយគ្នាយ៉ាងសុខដុមរមនា ( Syncrétisme religieux ) ដែលមានសិលាចារឹក និង រូបបដិមាអាចបញ្ជាក់បានយ៉ាងបរិបូណ៌ លើកលែងតែក្នុងរជ្ជកាលរបស់ព្រះបាទឧទយាទិត្យវរ្ម័នទី២ដែលមានការបះបោរបីលើក ហើយដែលគេឃើញពួកបះបោរដើរវាយកំទេចសិវលិង្គ និងទេវបដិមាចោល(19) ។

នៅស.វទី១២ គណៈវិស្ណុនិយមត្រូវបានព្រះបាទសូរ្យវរ្ម័នទី២ គោរពរាប់អានសម្បើមដូចមានប្រាសាទអង្គរវត្តជាសក្ខីភាពស្រាប់ ។ អង្គរវត្តមានទ្រង់ទ្រាយជាប្រាសាទភ្នំដដែល ប៉ុន្តែគឺសំរាប់តំកល់វិស្ណុបដិមាទៅវិញ រីឯក្បាច់រចនាក៏សុទ្ធតែទៅតាមបែបវិស្ណុនិយមទាំងអស់(រូបចម្លាក់រឿងរាមកេរ្តិ៍ រឿងមហាការតៈ រឿងកកូរសមុទ្រទឹកដោះ ។ ល ។) ។ ហេតុបានជាដូច្នេះព្រោះក្នុងពេលជាមួយគ្នានៅក្នុងប្រទេសឯទៀតៗក៏មានការនិយមគោរពព្រះវិស្ណុនេះដូចគ្នាដែរ ។

តពីនេះទៅ គេឃើញថាពុទ្ធសាសនាមហាយានដែលបាននាំចូលមកតាំងពីសម័យចេនឡា (ស.វ. ទី៨)ហើយដែលបានព្រះបាទសូរ្យវរ្ម័នទី១ កាន់ម្តងរួចហើយ(ស.វ.ទី១១)ត្រូវបានព្រះរាជាលើកតំកើងជា

សាសនាសំរាប់រដ្ឋតែម្តង ជាពិសេសក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី ៧ ។ ប្រាសាទបាយ័នដែលព្រះអង្គសាងឡើងនៅមានទ្រង់ទ្រាយជាប្រាសាទភ្នំ ហើយស្ថិតនៅកណ្តាលរាជធានីដដែល តែរូបតំណាងព្រះរាជាគឺជាពុទ្ធបដិមាទៅវិញ (ពុទ្ធរាជ) ។ ហេតុអ្វីបានជាមានការប្រែប្រួលយ៉ាងនេះ ? ត្រង់នេះគួរគប្បីជ្រាបថា ការវាយយកបានក្រុងអង្គរដោយទ័ពចាមនៅគ.ស. ១១៧៧ ហើយជាលើកទី១ផងនោះជាអន្លូងមួយយ៉ាងធ្ងន់វាយទៅលើលទ្ធិទេវរាជ ។ ប្រជារាស្ត្រទំនងជាចង់លែងជឿទៅលើប្រសិទ្ធភាពនៃលទ្ធិនេះទៀតហើយ ក៏ប៉ុន្តែពួកព្រាហ្មណ៍ជាបរិវារនៅមានឥទ្ធិពលខ្លាំងក្លាណាស់នៅឡើយ ទើបព្រះបាទជ័យវរ្ម័នទី៧ទ្រង់ឈ្វេងយល់ថាត្រូវតែរក្សាទុករបស់ចាស់ខ្លះ(មិនអាចកំចាត់ចោលភ្លាមៗបានទេ) ហើយយករបស់ថ្មីខ្លះមកប្រើដើម្បីអោយមានសង្ឃឹមដល់ប្រជារាស្ត្រដោយផ្សំធាតុសិវនិយមខ្លះ(ប្រាសាទភ្នំ)និងពុទ្ធនិយមខ្លះ(ពុទ្ធរាជ) ។ ដូច្នេះ យើងឃើញថាពុទ្ធសាសនាមហាយានបានមកដល់ទាន់ពេលវេលា ដើម្បីស្រោចស្រង់ជាតិអោយមានពន្លឺឡើងវិញក្រោយព្រឹត្តិការណ៍១១៧៧ ។ ដែលព្រះបាទជ័យវរ្ម័នទី៧ហ៊ានយកលទ្ធិនេះមកប្រើព្រោះពេលនោះពុទ្ធសាសនិកក៏មានកាន់តែច្រើនណាស់ហើយ ហើយម្យ៉ាងទៀតលទ្ធិនេះជាលទ្ធិបែបមនុស្សនិយម មានទំនោរទោរទៅរកជីវភាពប្រជារាស្ត្រទូទៅដូច រូបចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័នជាសក្ខីភាពស្រាប់ ហើយដើម្បីបង្ហាញអោយឃើញនូវព្រះហឫទ័យមេត្តាករុណាចំពោះប្រជារាស្ត្រនេះ ព្រះអង្គទ្រង់បានកសាងមន្ទីរពេទ្យ១០២សំរាប់ជនទាំង៤វណ្ណៈចូលព្យាបាលជម្ងឺបានដូចៗគ្នា ។ ទាំងនេះសអោយឃើញថា នៅចំពោះប្រជារាស្ត្រលទ្ធិពុទ្ធសាសនាមហាយានមានសមត្ថភាពមិនចាញ់លទ្ធិទេវរាជទេ គឺមានសមត្ថភាពការពារស្រោចស្រង់និងបំរើរាស្ត្របានដូចគ្នា ។

តែអកុសល ការផ្លាស់ប្តូរសាសនានៅតែមានបន្តទៅទៀត ។ ព្រះបាទជ័យវរ្ម័នទី៨ត្រឡប់ទៅរកសិវនិយមវិញដែលជាហេតុបណ្តាលអោយមានប្រតិកម្មយ៉ាងខ្លាំងក្លាពីពួកព្រាហ្មណ៍ប្រឆាំងនឹងពុទ្ធសាសនារហូតដល់មានការវាយកំទេចឬកោសលុបព្រះពុទ្ធបដិមាចោល ។ ស្ថានការណ៍បែបនេះទំនងជាមានសភាពរ៉ាំរ៉ៃរហូតដល់បដិវត្តន៍នាយត្រសក់ផ្អែមដែលបានយកពុទ្ធសាសនាហីនយានមកជំនួសជាស្ថាពររហូតមកដល់សព្វថ្ងៃនេះ ។

## ២.២. លទ្ធិបុគ្គលនិយម

ពីស.វ.ទី ៩ ដល់ស.វ.ទី ១២គេឃើញមានការកសាងរូបបដិមាជាច្រើននៃទេវ-ទេវី ឬ ពោធិសត្វ ប៉ុន្តែរូបបដិមាទាំងនោះពុំមែនតំណាងទេវ-ទេវីឬពោធិសត្វចំៗទាំងអស់ទេ មួយភាគធំជាតំណាងព្រះរាជា រាជវង្សានុវង្ស រាជគ្រូឬជនដែលមានគុណចំពោះជាតិដែលគេលើកតំកើងអោយមានឋានៈស្មើទេវ-ទេវី ឬពោធិសត្វ ។ ឈ្មោះនៃរូបបដិមាទាំងនោះសុទ្ធតែកើតឡើងដោយការផ្សំនាមផ្ទាល់នៃបុគ្គលដែលគេគោរពជាមួយនឹងនាមទេវ-ទេវីឬពោធិសត្វ ។

គួរគប្បីសង្កេតថា លទ្ធិបុគ្គលនិយមនេះមានសភាពរុងរឿងយ៉ាងខ្លាំងនៅចុងស.វ.ទី១២ ។ យ៉ាងណាមិញ សិលាចារឹកភិមានាកាសបាននិយាយថាព្រះនាងជ័យរាជទេវី អគ្គមហេសីរបស់ព្រះបាទ ជ័យវរ្ម័នទី ៧ "បានសាងនៅគ្រប់ទិសទីនូវរូបបដិមានៃព្រះបិតា ព្រះមាតា បងប្អូនញាតិមិត្តដែលព្រះនាងបានស្គាល់ច្បាស់ឬគ្រាន់តែឮគេនិយាយប្រាប់ " ។ ម្យ៉ាងទៀតក្រោយពីព្រះនាងចូលទីវង្គតទៅ បងស្រីរបស់ព្រះនាងនាមឥន្ទ្រទេវី "បានសាងរូបបដិមារបស់ព្រះនាងយ៉ាងច្រើន របស់ព្រះរាជានិងរបស់ព្រះនាងផ្ទាល់នៅពាសពេញទីក្រុង " ។

## ៣. សេដ្ឋកិច្ចនិងសិល្បៈ

លទ្ធិទេវរាជបានផ្តល់អោយព្រះរាជានូវឋានៈអាទិទេព ប៉ុន្តែអាទិទេពនេះមិនមែនស្ថិតដាច់ពីមនុស្សលោកទេ ព្រះអង្គគង់នៅជាមួយមនុស្សហើយមានការមើលសុខទុក្ខរបស់ប្រជារាស្ត្រថែមទៀតផង ។ ដូច្នេះដើម្បីបង្ហាញអោយឃើញថាព្រះអង្គមានមហិទ្ធិរិទ្ធិខ្លាំងពូកែសមឋានៈជាអាទិទេពមែននោះព្រះអង្គត្រូវខិតខំធ្វើយ៉ាងណាអោយប្រជារាស្ត្របានស្គាល់នូវភាពសម្បូរណ៏សប្បាយរុងរឿងយ៉ាងពិតប្រាកដ ។ ដោយហេតុនោះព្រះអង្គត្រូវធ្វើយ៉ាងណាអោយកសិកម្មលូតលាស់ជាអតិបរិមា គឺត្រូវធ្វើអោយមានទឹកបរិបូណ៌មិនបាច់ពឹងពាក់ទៅលើទឹកភ្លៀងទៀត ដោយការកសាងបារាយធំៗដែលមានសល់ខ្លះរហូតមកដល់សព្វថ្ងៃនេះផង ។ កិច្ចការនេះ រាស្ត្របានរួបរួមគ្នាបំពេញដោយស្មោះស្ម័គ្រជាទីបំផុត ព្រោះមានជំនឿយ៉ាងមាំទៅលើលទ្ធិទេវរាជដែលមានប្រសិទ្ធភាពអាចធ្វើការបង្រួបបង្រួមជាតិផងរំដោះប្រទេសជាតិអោយរួចផុតពីបរទេសផង ។ បើតាមលោកជីវតាក្វាន់ ខ្មែរនៅសម័យនោះអាចធ្វើស្រែបាន៣ទៅ៤ដងក្នុងមួយឆ្នាំ (30) ។ លោក Henri Stierlin អ្នកឯកទេសជាតិស៊ីសម្នាក់បានគន់គួរឃើញថា នៅលើផ្ទៃដី១០០០គ.ម.ក្រឡានៅតំបន់អង្គរគេអាចផលិតស្រូវបានក្នុងមួយឆ្នាំប្រហែល ១៥០ ០០០តោន ដែលអាចចិញ្ចឹមប្រជាជនបានដល់ទៅ៨០០ ០០០នាក់ ហើយនៅសល់៤០%ទៀតអាចនាំយកទៅផ្តល់អោយតំបន់ផ្សេងៗទៀត (35) ។

គឺការចំរើនលូតលាស់ខាងសេដ្ឋកិច្ចនេះហើយដែលអនុញ្ញាតអោយប្រជារាស្ត្រចូលរួមក្នុងការកសាងប្រាសាទតាមតំរូវការរបស់លទ្ធិទាំងពីរ គឺលទ្ធិទេវរាជនិងលទ្ធិបុគ្គលនិយម ។ ដូច្នេះ ក្នុងស្ថាបត្យកម្មសម័យនោះគេសង្កេតឃើញមានប្រាសាទពីរបែប :

១. ប្រាសាទភ្នំជាប្រាសាទសង់លើឿនច្រើនជាន់សំរាប់លទ្ធិទេវរាជ (បាគង បាខែង បក្សីចាំក្រុង ប្រាសាទធំ មេបុណ្យខាងកើត ប្រែរូប តាកែវ បាពួន អង្គរវត្ត បាយ័ន) ។

២. ប្រាសាទសង់ទាបនឹងដីជាប្រាសាទសំរាប់លទ្ធិបុគ្គលនិយម ( ព្រះគោ លលៃ បន្ទាយឆ្មារ ព្រះខាន់ តាព្រហ្ម ។ ល ។) ។ ម្យ៉ាងទៀតគេបានសង្កេតឃើញថាពីរាជមួយទៅរាជមួយទៀតប្រាសាទ

មានទំហំកាន់តែធំឡើង ហើយកាន់តែច្រើនឡើង ។ ត្រង់នេះបង្ហាញអោយឃើញថា ព្រះរាជាអង្គរហាក់ដូចជាបានប្រណាំងប្រជែងក្នុងការលើកកិត្យានុភាពរបស់ព្រះអង្គ ។ ចំពោះប្រាសាទដូចបានរៀបរាប់រួចមកហើយនេះ ពុំមែនមានត្រឹមតែការកសាងហើយចប់នោះទេ គឺប្រជារាស្ត្រមានការផ្គត់ផ្គង់នូវគ្រឿងប្រដាប់ប្រើប្រាស់ និងជង្វាយផ្សេងៗ និងមានភារៈត្រូវទៅនៅបំរើ និងថែរក្សាប្រាសាទទាំងនោះថែមទៀត ។ ឧទាហរណ៍ៈ ដូចជាប្រាសាទតាព្រហ្មកសាងឡើងនៅឆ្នាំ១១៨៦ ដោយព្រះបាទជ័យវរ្ម័នទី៧ សំរាប់ឧទ្ទិសចំពោះវិញ្ញាណក្ខន្ធនៃព្រះមាតានិងព្រះគ្រូនិងបដិមារូបឯទៀតចំនួន ២៦០ មានភូមិចំណុះ ៣១៤០ភូមិ (សំរាប់ផ្គត់ផ្គង់ប្រដាប់ប្រើប្រាស់ និងជង្វាយផ្សេងៗ) មានមនុស្សនៅចាំបំរើនិងថែរក្សា ៧៩៣៦៥នាក់ (ក្នុងចំណោមនេះមាន១២ ៦៤០នាក់ ស្ថិតនៅក្នុងបរិវេណប្រាសាទជានិច្ច) ។ គ្រឿងប្រដាប់ប្រើប្រាស់ជាជង្វាយមាន ៖ ចានមាសទម្ងន់ជាង៥តោន ចានប្រាក់មួយទម្ងន់ដូចគ្នា ពេជទាំងគ្រាប់ធំ ៣៥គ្រាប់ ត្បូងមុក្តា៤០៦២០គ្រាប់ ត្បូងយ៉ាងល្អ៤៥៤០គ្រាប់ ផ្ដិលមាសធំមួយ រនាំងស្រុកចិន ៩៦៧ គ្រែធ្វើដោយសំពត់ល្អ ៥១២ ក្លស់ ៥២៣ ។ ចំពោះស្បៀងអាហារមាន ៖ អង្ករ-ស្ករ-ទឹកដោះគោ-ប្រេង-ទឹកឃ្មុំ-ក្រមួន-ខ្លឹមចន្ទន៍-កប្បូរ-គ្រឿងចីវរ ។ នេះចំពោះប្រាសាទតែមួយផង ឃើញថាការប្រើប្រាស់កម្លាំងមនុស្ស និងទ្រព្យសម្បត្តិអស់យ៉ាងសន្ធឹកសន្ធាប់ទៅហើយ ចុះបើខ្មែរយើងមានប្រាសាទដល់ទៅរាប់ពាន់តើតម្រូវការទាំងខាងកម្លាំងមនុស្សទាំងខាងទ្រព្យសម្បត្តិមានដល់ប៉ុន្មាន? ចំពោះបញ្ហានេះប្រវត្តិវិទូជាច្រើនបានចាត់ទុកថា ការកសាងប្រាសាទរួមនិងចម្បាំងដ៏វែងឆ្ងាយ (សូរ្យ-វរ្ម័នទី២ វាយយួនផង ចាមផង មនផង)ជាកត្តាមួយនៃការធ្លាក់ចុះនៃអរិយធម៌អង្គរនេះឯង ។

22 - B .P. Groslier, Angkor et le Cambodge au 16è siècle d´après les sources portugaises et espangnoles, PUF, Paris 1958

23- Jean Delvert, le Paysan Cambodgien, Mouton & Co La Haye, Paris 1961

24 - E. Aymonie, le Cambodge. t . III, Paris 1904.

25 - ភិក្ខុប៉ាងខាត់ -ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ - ភ្នំពេញ ១៩៦១ ។

26 - Subhadradis Diskul. Art in Thailand, A brief history, Bangkok, 1971.

27 - Louis Finot, Les inscriptions de Mison ( n°II) ,BEFEO, IV.

28 - P -Pelliot, Le Founan, BEFEO.t.III.

29 - Louis Renou et Jean Filliozat . l´Inde classique . tomed , Hanoi , 1953 .

30 - Paul Pelliot, Mémoires sur les Coutumes du Cambodge de Tchéou Ta-Kouan, Paris, 1951.

31 - Tran Trong Kim, Viet Nam Su luoc , Saigon , 1964 .

32 - D Meunier, Histoire du Cambodge, PUF . Que sais - je ? Paris, 1961 .

33 - L. Finot, L´Inscription de Sdok Kak Thom, BEFEO, XV, 2.

34 - Philippe Stern, le temple - montagne Khmer. Le culte du linga et le devaraja, BEFEO, tome XXXIV, Fasc.2,1934 .

35 - Henri Stierlin, Un chef-d´oeuvre d´équilibre écologique, dans SOS. Angkor, Courrier de l´Unesco, Décembre, 1961.

36 - Georges Coedès, Pour mieux comprendre Angkor, Paris, 1947 .

37 - Mubin sheppard, Taman Indera, Oxford University Press, Kuala Lumpur Singapour, London, Melbourne New York , 1972 .

38 - G. Coedès, Recueil des Inscriptions du Siam, 2è partie.

39 - M. Giteau, Histoire du Cambodge, Didier, Paris, 1957 .

40 - J . Imbert, Histoire des Institutions khmères, volume ll, Annales de la Faculté de Droit de Phnompenh , 1961 .